CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ សម្រាប់ខែវិច្ឆិកា ឆ្នាំ២០១៦ លក់តម្លៃ ១០០០រៀល

លេខ ៩៧

# វាចាពលរដ្ឋ៖ ទាល់តែប្រមុខរដ្ឋាភិបាល បញ្ជាទើបសមត្ថកិច្ចសកម្មឬ?



ថតដោយសាហការី ស៊ីអេសស៊ី

## សេចក្ដីជូនដំណឹង

" លោហិតមរណសាក្សី គឺគ្រាប់ពូជរបស់ព្រះសហគមន៍ " (Apologeticus, Chapter 50:Tertullian)។ បងប្អូន ជាទីស្រឡាញ់ ព្រះសហគមន៍កាតូលិកកម្ពុជារីកចម្រើនដោយសារឈាមមរណសាក្សី។ ខ្ញុំលោកបូជាចារ្យ រឿង ផ័ត្រសិរី អ្នករៀបចំសំណុំរឿង (Postulator) បានប្រមូលព័ត៌មានមួយចំនួនហើយ ប៉ុន្តែសូមបងប្អូនជួយផ្ដល់ព័ត៌មានបន្ថែម អំពីអ្នកបម្រើរបស់ព្រះជាម្ចាស់ថែមទៀតដូចជា រូបថត អត្ថបទ ឬសៀវភៅដែលគាត់សរសេរវត្ថុអនុស្សាវរីយរបស់គាត់ខ្លះ។ល។ សូមផ្ដល់ឈ្មោះអ្នកដែលអាចផ្ដល់សក្ខីភាពបានជូនមកឲ្យខ្ញុំតាមរយៈអាសយដ្ឋានខាងក្រោម

Tel : 077 800 211 / 096 34 22 144
ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ
Email: martyrscambodia@gmail.com



សូមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ

ប្រទានព្រះពរមហាប្រសើរថ្វាយ

ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសគម្រប់ខួបលើកទី១២

នៃការគ្រងរាជសម្បត្តិ។

សូមព្រះយេស៊ូគ្រីស្ត ជាអម្ចាស់ដែលជាប្រភពនៃសេចក្តីសុខសាន្តប្រទាន

ព្រះប្រាជ្ញាញាណ និងព្រះកាយពលបរិបូរណ៌ ថ្វាយព្រះករុណា

ដើម្បីគង់ជាម្លប់ដល់ប្រជារាស្ត្រកម្ពុជាបានទទួលសុខសន្តិភាពជាដរាបតរៀងទៅ!

ក្រាបបង្គំទូលថ្វាយពីព្រះសហគមន៍កាតូលិកកម្ពុជា

# ប្រជាពលរដ្ឋថៃបាត់បង់មហាក្សត្រដែលបានគ្រងរាជសម្បត្តិយូរជាងគេនៅលើពិភពលោក



ប្រជាពលរដ្ឋថៃដែលមានចំនួនប្រមាណជា ៦៥ លាននាក់ បានបាត់បង់មហាក្សត្ររបស់ពួកគេ កាលពីថ្ងៃព្រហស្បត្តិ៍ ទី១៣ ខែតុលា ឆ្នាំ២០១៦។

ចាប់ពីថ្ងៃទី១៣ ខែតុលា នេះតទៅពួកគេនឹងកាន់ទុក្ខនៃការសោយទិវង្គតរបស់មហាក្សត្រ ភូមិបុល អាឌុលយ៉ាដេតរយៈពេលមួយឆ្នាំ។ ដោយឡែកការឡើងគ្រងរាជ្យរបស់រាជបុត្រស្នងរាជថៃ ក៏ត្រូវពន្យារពេលមួយឆ្នាំផងដែរ។

លោក ព្រេម ទិនស៊ូឡាណុន អតីតនាយករដ្ឋមន្ត្រី និងជាឧត្តមសេនីយមួយរូបដែលមានវ័យចំណាស់ ប្រមាណជា ៩០ឆ្នាំនោះត្រូវបានតែងតាំងជារាជានុសិទ្ធិសម្រាប់ដឹកនាំរាជកិច្ចបណ្តោះអាសន្ននៅក្នុងអំឡុងពេលនៃការកាន់ទុក្ខ និងពេលគ្មានមហាក្សត្រ។

យោងទៅតាមប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសថៃបានឲ្យដឹងថានៅក្រោយពេលដែលមហាក្សត្រថៃបានសោយទិវង្គត លោកនាយករដ្ឋមន្ត្រីថៃ ប្រាយុទ្ធ ចាន់អូចា បាននិយាយថា រាជទាយាទមហា វិជ្ជ៉ាឡុងកននឹងត្រូវយាងឲ្យសោយរាជសម្បត្តិជាមហាក្សត្រនៃប្រទេសថៃប៉ុន្តែទ្រង់បានឆ្លើយតបថាទ្រង់ចង់កាន់ទុក្ខជាមួយនឹងប្រជាពលរដ្ឋសិន ។

មហាក្សត្រ ភូមិបុល បានតែងតាំងព្រះអង្គម្ចាស់មហា វិជ្ជ៉ាឡុងកន ជារាជទាយាទស្នងរាជ្យនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៧២។ នៅពេលបច្ចុប្បន្ននេះព្រះរាជទាយាទមានព្រះជន្ម ៦៤ វស្សាហើយ។

ទ្រង់គឺជារាជបុត្រាតែមួយអង្គគត់របស់មហាក្សត្រភូមិបុលដោយទ្រង់បានទទួលការអប់រំក្នុងប្រទេសអង់គ្លេស និងចូលរៀនមហាវិទ្យាល័យភូមិន្ទយោធាអូស្រ្តាលី ( Royal Military College ) នៅដាន់ត្រូន ( Duntroon ) ទីក្រុងកង់បេរ៉ា។

រាជទាយាទជាមន្ត្រីដែលបម្រើការក្នុងកងភូមិន្ទថៃ និងបំពេញទស្សនកិច្ចញឹកញាប់ជុំវិញប្រទេស ក្នុងឋានៈជាព្រះរាជតំណាងបិតារបស់ទ្រង់ នៅក្នុងព្រឹត្តិការណ៍ និងពិធីផ្លូវការជាច្រើន។

តាមសេចក្តីរាយការណ៍ នៅក្នុងនាមជាទាហានមួយរូបទ្រង់បានដឹកនាំយុទ្ធនាការប្រឆាំងចលនាផ្តាច់ខ្លួនរបស់ពួកកុម្មុយនីស្តក្នុងប្រទេសថៃក្នុងទសវត្សរ៍ ១៩៧០។ ទ្រង់ក៏ជាអ្នកបើកបរយន្តហោះចម្បាំង និងមានសមត្ថភាពបើកយន្តហោះស៊ីវិលធំៗញឹកញាប់ដែរ។ ក្នុងនាមជារាជទាយាទ ទ្រង់មានកងវរសេនាតូចនៃទាហានវរជនចំនួន ៦ ក្រោមបញ្ជារបស់ទ្រង់។ ក្រៅពីនេះ ទ្រង់ក៏បានបង្កើតមន្ទីរពេទ្យជាច្រើនកន្លែងនៅតំបន់ជនបទផងដែរ។ ត្រឹមឆ្នាំ ១៩៩៧ មន្ទីរពេទ្យរបស់រាជទាយាទបានសាងសង់ឡើងចំនួន២១ កន្លែង។

រាជទាយាទអង្គនេះធ្លាប់រៀបអភិសេកចំនួន ៣ លើកដោយមហេសីទីមួយរបស់ទ្រង់ គឺជាប្អូនស្រីជីដូនមួយ ព្រះនាម សោមសាវ៉ាលីគីទីយ៉ាកា៉រា (SoamsavaliKitiya-kara)។ ទ្រង់ទាំងពីររៀបអភិសេកក្នុងឆ្នាំ ១៩៧៧ និងមានបុត្រីមួយអង្គ ប៉ុន្តែបានលែងលះក្នុងឆ្នាំ១៩៩៣។ ទ្រង់បានរៀបអភិសេកជាលើកទីពីរជាមួយតារាសម្តែងនាង យូ៉វ៉ាដហ៊ីដា ប៉ុលស្រាសឹត (Yuvadhi-daPolpraserth) ហើយមានបុត្រចំនួន ៥ អង្គ។ នាឆ្នាំ២០០១ រាជទាយាទក៏រៀបអភិសេកជាលើកទីបីជាមួយកញ្ញា ស្រីរស្មី អាខា៉រាផុងព្រីឆា (SrirasmiAkharaphong-preecha) ដោយមានបុត្រាមួយអង្គ គឺឌីប៉ាងកន រស្មីចូទី (DipangkornRasmijoti) ឥឡូវអាយុ ១១វស្សា។ បច្ចុប្បន្ននេះ មហេសីចុងក្រោយអង្គនេះបានត្រូវលែងលះជាថ្មីដោយសារតែញាតិសន្តានរបស់ទ្រង់មានរឿងអាស្រូវពុករលួយ និងល្មោភអំណាច។

នៅក្នុងនាមជាព្រះរាជទាយាទទ្រង់ត្រូវបានគេដឹងថាមានទាំងគុណសម្បត្តិនិងគុណវិបត្តិដោយទ្រង់ធ្លាប់មានរឿងអាស្រូវមួយចំនួនហើយគុណសម្បត្តិវិញក៏សំបូរដោយរួមទាំងសកម្មភាពសង្គមផ្សេងៗនាពេលកន្លងមក ។ *ដោយ អរិយបុត្រ*

# លោកអភិបាល ឲ្យគ្រីស្តបរិស័ទបង្ហាញមេត្តាករុណានិងកសាងសន្តិភាព

លោកអភិបាល អូលីវីយេ បានថ្លែងក្នុងធម្មទេសនាថា យើងត្រូវយកចិត្តទុកដាក់ដើម្បីកសាងសុខសន្តិភាពនៅក្នុងសង្គមរបស់យើង។ លោកបានមានប្រសាសន៍នេះ ក្នុងឱកាសបុណ្យភ្នំដែលព្រះសហគមន៍បានប្រារព្ធធ្វើនៅលើភ្នំបូកគោក្នុងខេត្តកំពត នៅក្នុងព្រះវិហារចំណាស់មួយ កាលពីថ្ងៃទី៣០ កញ្ញា កន្លងទៅ។

លោកអភិបាលបានប្រសាសន៍បន្តថា ដើម្បីកសាងសុខសន្តិភាពបាន សូមឲ្យយើងមើលគំរូរបស់ឧបការីរបស់យើងដូចជា លោកគ្រីស្យង់ ហ្គោកីឡាំង ដេប៉ាលីយ៉េរ (PAPY) ជាស្ថាបនិកអង្គការភាពញញឹមនៃកុមារ លោក René Péchard ជាស្ថាបនិកអង្គការកុមារមេគង្គ លោក Shimon Peres ជាអតីតនាយករដ្ឋមន្ត្រីប្រទេសអ៊ីស្រាអែល អ្នកម្តាយតេរេសា សន្ត ហ្វ្រង់-ស្វ័រ នៃទីក្រុងអាស៊ីស៊ី និងសន្តសន្តីបុគ្គលជាច្រើនទៀតដែលបានខិតខំបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ និងខិតខំកសាងសន្តិភាពសម្រាប់ពិភពលោក។

លោកអភិបាល បានបន្តទៀតថា "យើងជាគ្រីស្តបរិស័ទកាតូលិកត្រូវធ្វើជាព្រះអាទិត្យថ្មី ដែលពោរពេញដោយធម៌មេត្តាករុណា សេចក្តីស្រឡាញ់ ការលើកលែងទោសរបស់ព្រះជាម្ចាស់រះលើផែនដីចាស់របស់យើង ដើម្បីឲ្យយើងអាចកសាងសង្គមថ្មីដែលស្របតាមគម្រោងការណ៍របស់ព្រះយេស៊ូ"។

នៅចុងបញ្ចប់នៃអភិបូជា លោកអភិបាល លោកបូជាចារ្យ បងប្រុសបងស្រី និងបងប្អូនគ្រីស្តបរិស័ទទាំងអស់ប្រមាណ ២០០នាក់ បានដង្ហែព្រះឈើឆ្កាងរួមជាមួយម្ហូបអាហារ និងឈ្មោះឧបការីរបស់ខ្លួនទៅលើភ្នំ ដើម្បីគោរពថ្វាយបង្គំនិងអធិដ្ឋាន ជាពិសេសដើម្បីរំលឹកដល់ ថ្ងៃដែលគេឆ្កាងព្រះយេស៊ូនៅលើភ្នំលលាដ៍ក្បាល។ ក្រោយមកក៏មានការបរិភោគអាហារថ្ងៃត្រង់រួមគ្នា។ *ដោយសុធីរិទ្ធ*



*ថតដោយ សុធីរិទ្ធ*

# ផ្អកស្មៅជាអាហារសត្វពាហនៈដែលកសិករគួរតែរិះគិតនិងស្វែងយល់

សត្វពាហនៈនៅកម្ពុជាត្រូវបានគេដឹងថា គឺជាកម្លាំងស្នូលមួយដ៏សំខាន់របស់កសិករ ដោយសារពួកវាក្រៅពីជាកម្លាំងអូសទាញសម្រាប់វិស័យកសិកម្មហើយនោះ ពួកវានៅជាប្រភព ចំណូលគ្រួសារមួយដ៏ចម្បង ដូច្នេះការរិះគិតនិងស្វែងយល់អំពីអាហាររបស់ពួកវា គួរតែជាចំណុចមួយដែលកសិក គួរយកចិត្តទុកដាក់ ។

យោងទៅតាមឯកសាររបស់អង្គការជប៉ុនមួយដែលមានឈ្មោះថា JLTA បានឲ្យដឹងថា ផ្អកស្មៅ គឺជាអាហារសត្វពាហនៈមួយ ដែលកសិករគួរតែរិះគិត និងស្វែងយល់។

ប្រភពដដែលបានឲ្យដឹងថា នៅក្នុងការចិញ្ចឹមសត្វពាហនៈជាពិសេស គឺសត្វគោ និងក្របី ការស្វែងរកចំណីពីធម្មជាតិគឺមិនទាន់គ្រប់គ្រាន់ទេ ដូច្នេះការយករបស់ធម្មជាតិ មកកែច្នៃជាចំណីផ្សេងៗ អាចធ្វើឲ្យសត្វពាហនៈមានចំណីគ្រប់គ្រាន់ និងទទួលជីវជាតិប្រូតេអ៊ីនគ្រប់គ្រាន់សម្រាប់ការលូតលាស់ផងដែរ។

ស្មៅធម្មជាតិនៅកម្ពុជាសំបូរ ប៉ុន្តែជាទូទៅគឺសំបូរតែនៅរដូវវស្សា ដូច្នេះហើយនៅតាមភូមិស្រុកជាច្រើនគេសង្កេតឃើញថា រូបរាងសត្វពាហនៈមានសភាពស្រស់ថ្លា ធាត់មានសាច់មានឈាម គឺនៅពេលនោះ ប៉ុន្តែនៅពេលឈានដល់រដូវប្រាំង ស្មៅធម្មជាតិ គឺមានការខ្វះខាតសឹងតែគ្រប់កន្លែង ដោយកសិករខ្លះត្រូវធ្វើដំណើរទៅរកស្មៅសត្វពាហនៈនៅទីដៅឆ្ងាយៗ រាល់ថ្ងៃបណ្តាលឲ្យខាតបង់ទាំងពេលវេលា កម្លាំងពលំ និងលុយកាក់ផងដែរ។ ដូច្នេះ ផ្អកស្មៅជាជម្រើសជួយសម្រួលកសិករមួយផ្នែក ប្រសិនជាយើងនាំគ្នាស្វែងយល់ពីវា។

ប្រភពបានឲ្យដឹងថា ផ្អកស្មៅ គឺជាស្មៅឬរុក្ខជាតិ នៅស្រស់ដែលកាត់ជាកំណាត់ល្អិតៗ ហើយរក្សាទុកនៅកន្លែងគ្មានខ្យល់ ដោយដាក់ក្នុងធុងបិទជិត ឬថង់ប្លាស្ទិកបិទជិត។ វា គឺជាអាហារដែលមានសារជាតិបំប៉នដែលអាចជួយឲ្យសត្វពាហនៈអាចលូតលាស់បានលឿន ហើយវាអាចរក្សាទុកបានយូរ ជាពិសេសកសិករអាចទុកប្រើប្រាស់នៅរដូវខ្វះចំណី។

ឯកសារបានឲ្យដឹងថា មុននឹងធ្វើផ្អក-ស្មៅ កសិករត្រូវផលិតទឹកមេផ្អកស្មៅសិន។ កសិករអាចផលិតបរិមាណទឹកមេផ្អក-ស្មៅដោយខ្លួនឯងអាស្រ័យលើតម្រូវការដាក់ស្តែងសម្រាប់ផលិតផ្អកស្មៅជាចំណីគោ ឬក្របី។ ទឹកមេផ្អកស្មៅនេះអាចរក្សាទុកបានត្រឹមតែមួយអាទិត្យប៉ុណ្ណោះ ហើយដើម្បីផលិតទឹកមេផ្អកស្មៅ មួយដបកសិករត្រូវរកស្មៅស្រស់ទម្ងន់ ០,៥គីឡូក្រាម ស្ករទម្ងន់២ក្រាម ទឹកសុទ្ធចំណុះ ០,៥លីត្រ និងប្រដាប់វាស់កំហាប់ប៉េហាស (PH) មួយ។ កសិករបុកស្មៅស្រស់ទាំងចំនួន ០,៥គីឡូក្រាម ឲ្យម៉ត់ រួចពួតយកទឹកស្មៅ និងច្រោះឲ្យបានថ្លាល្អ និងស្អាតជាមួយកម្រងក្រណាត់ស្អាត ដែលមិនមានជាប់សារធាតុផ្សេងៗ ដូចជាជាតិប្រៃ សាប៊ូជាដើម។ កសិករយកទឹកស្មៅដែលច្រោះទៅលាយជាមួយស្ករ២ក្រាម និងទឹកចំណុះ ០,៥លីត្រ បន្ទាប់មកច្រកចូលទៅក្នុងដបកែវស្អាត រួចបិទដបឲ្យជិតមិនឲ្យខ្យល់ចេញចូល។ ទឹកមេផ្អកស្មៅត្រូវរក្សាទុកកន្លែងត្រជាក់ល្មម ពោលគឺមិនក្តៅ និងមិនត្រជាក់ ក្នុងរយៈពេលបីថ្ងៃ បន្ទាប់មកត្រូវយកដបមកពិនិត្យមើលគុណភាព និងវាស់កំហាប់របស់ទឹកមេផ្អកស្មៅ។ កំហាប់ល្អគឺស្ថិតក្នុងចន្លោះពី៣ ទៅ ៤,៥ ប៉េហាស។

កសិករមិនអាចយកទឹកមេផ្អកស្មៅមកប្រើដោយផ្ទាល់ទេ។ ទឹកមេផ្អកស្មៅមួយដប ត្រូវយកទៅលាយទឹកបន្ថែមចំណុះ ១០លីត្រ ជាមុនសិន ទើបអាចលាយធ្វើជាផ្អកស្មៅបាន។ ដំបូងកសិករត្រូវច្រូតស្មៅស្រស់ រួចដាក់ហាលឲ្យស្រពាប់។ កសិករហាន់ ឬកាប់ចិញ្ច្រាំស្មៅស្រស់ឲ្យល្អិតតូចៗ។ កសិករប្រោះ ឬបាញ់ ទឹកមេផ្អកស្មៅដែលលាយទឹករួច ឲ្យសព្វល្អក្នុងបរិមាណ០,៥លីត្រ សម្រាប់ស្មៅ ២០គីឡូក្រាម។ កសិករច្រកស្មៅចូលក្នុងថង់ប្លាស្ទិក ឬធុងមានថង់ប្លាស្ទិកខាងក្នុងបន្តិចម្តងៗ ដោយជាន់បង្ហាប់ឲ្យណែនផង។ កសិករត្រូវចងថង់ប្លាស្ទិកដោយមិនឲ្យមានខ្យល់ខាងក្នុង។ បើអាចគាត់ត្រូវបឺតខ្យល់ចេញពីថង់ រួចចងកុំឲ្យខ្យល់ចេញចូល។ កសិកររក្សាទុកផ្អកស្មៅយ៉ាងតិចចំនួនបីអាទិត្យ ទើបអាចយកទៅផ្តល់ឲ្យគោស៊ី។

ប្រភពដដែលបានបន្តថា ផ្អកស្មៅដែលល្អមានពណ៌លឿងចាស់ និងមានក្លិនឈ្ងុល។ ប្រសិនបើផ្អកស្មៅមានពណ៌ក្រម៉ៅ ប្រផេះ ឬដុះផ្សិត មិនត្រូវផ្តល់ឲ្យគោក្របីស៊ីទេ។ កសិករអាចផ្តល់ចំណីផ្អកស្មៅឲ្យគោក្របីស៊ីជារៀងរាល់ថ្ងៃទៅតាមបរិមាណដែលមាន។ គោមួយក្បាលអាចស៊ីផ្អកស្មៅចំនួន ១គីឡូក្រាមក្នុងមួយថ្ងៃ ដោយលាយជាមួយនឹងចំណីផ្សេងៗទៀតដូចជា ចំបើង ឬស្មៅជាដើម។

បើនិយាយអំពីផ្អកស្មៅនេះ វាអាចនឹងចម្លែក ចំពោះកសិករទូទៅ ប៉ុន្តែចំពោះសហគមន៍ នៅក្នុងភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែល បច្ចុប្បន្ននេះបានក្លាយទៅជាភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌមានជ័យ រាជធានីភ្នំពេញ គឺជាអាហារដែលកសិករមួយចំនួនកំពុងតែផលិត ដើម្បីសត្វពា-ហនៈរបស់ពួកគាត់។ នេះបើតាមឯកសាររបស់អង្គការខាងលើ ។

លោក សុញ ចម្រើន ជាកសិករនៅឃុំមហាលាភ ស្រុកកោះសុទិន ខេត្តកំពង់ចាម បានឲ្យដឹងថា លោកធ្លាប់បានចិញ្ចឹមគោ និងប្រើប្រាស់គោជាច្រើននឹមមិនតែប៉ុណ្ណោះលោកក៏ធ្លាបដើរទិញគោសឹងតែគ្រប់កន្លែងនៅក្នុងប្រទេស ប៉ុន្តែនៅមិនទាន់ដែលឮ អំពីផ្អកស្មៅនេះនៅឡើយទេ ។

លោកបានបន្តថា ប្រសិនបើអាចដឹងអំពីវិធីដែលយើងអាចនឹងធ្វើផ្អកស្មៅនេះបាន វាគឺជារឿងដែល ប្រសើរមួយដែរ ដោយសារតែនៅខែប្រាំង គឺពិបាកដើររកស្មៅគោណាស់ ។

លោកបានបញ្ជាក់ថា "ខែវស្សាដូចឥឡូវ ចងវាឲ្យតែស៊ីជុំវិញតែភូមិ ក៏វាឆ្អែតដែរ ប៉ុន្តែបើខែប្រាំងវិញ សុទ្ធតែជិះកង់ជួនកាលជិះម៉ូតូទៅវាលបឹងរាប់គីឡូ ទើបមានស្មៅច្រូតឲ្យវាស៊ី"។

លោកបានបន្តទៀតថា វាម៉្យាងដែរ ប្រសិនបើយើងអាចទៅរកស្មៅត្រឹមតែមួយអាទិត្យម្តង ហើយយកមក ធ្វើជាផ្អកស្មៅនេះទុកឲ្យវាស៊ី។ លោកបានបញ្ជាក់ថា "វាមិនល្អស្អីទេ គឺវាចំណោញពេល ខ្ជិលទៅរកស្មៅរាល់ថ្ងៃ"។





ថតដោយ រិទ្ធី

ដោយ ផាត សំភី

# យុវជនសម័យនេះហាក់ដូចជាចាប់អារម្មណ៍នឹងទីផ្សារតាមអនឡាញ




*រូបថតពី ហ្វេសប៊ុក*

សម័យកាលកាន់តែទំនើបបច្ចេកវិទ្យាកាន់តែទាន់សម័យជាពិសេសប្រព័ន្ធ អ៊ីនធឺណេតកាន់តែទូលាយធ្វើឲ្យមនុស្សម្នារទូទាំងពិភពលោកងាកមកប្រើប្រាស់ទូរស័ព្ទទំនើបៗដែលភាសាអងគ្លេសហៅថា ស្មាតហ្វូន (Smart Phone) ឬភាសាខ្មែរហៅថា ទូរស័ព្ទវៃឆ្លាត គឺរីកដូចផ្សិត។

ក្នុងនោះគេសង្កេតឃើញថាការចាប់ផ្តើមបង្កើតទីផ្សារតាមប្រព័ន្ធអ៊ីនធឺណេតដែលគេចូលចិត្តនិយាយថា លក់តាមអនឡាញ(Online marketing) ក្នុងប្រទេសកម្ពុជាក៏មិនធម្មតាដែរ ដូចជាការលក់សម្លៀកបំពាក់ ទូរស័ព្ទ គ្រឿងសំអាងផ្សេងៗ ក៏ដូចជារបស់របរជាច្រើនមុខទៀតដែលនាំចូលពីក្រៅប្រទេសធ្វើឲ្យគេរកចំណូលបានច្រើនដោយក្នុងនោះអតិថិជន គឺភាគច្រើនជាយុវជន។

អ្នកស្រីពេជ វីយ៉ាដា ជាប្រជាពលរដ្ឋរស់នៅទីក្រុងភ្នំពេញនិងមានមុខរបរជាអ្នកលក់តាម (Online) បានឲ្យដឹងថា អ្នកស្រីបានជ្រើសរើសយកប្រព័ន្ធបណ្តាញសង្គមហ្វេសបុក (Facebook) ជាកន្លែងធ្វើទីផ្សារ។

អ្នកស្រីបានបន្តថា ការផ្សព្វផ្សាយអំពីហាងរបស់លោកស្រី តាមរយៈហ្វេសបុកនេះ គឺអ្នកស្រីបានចាប់ផ្តើមរយៈពេល៣ឆ្នាំមកហើយដោយតាំងពីដំបូងឡើយគឺអ្នកស្រីលក់សម្លៀកបំពាក់ បន្ទាប់មកទើបជ្រើសរើសយកគ្រឿងសំអាងផ្សេងៗ ដូចជា ឡេលាបខ្លួនឲ្យសរលឿន ម្សៅលាបមុខ ថ្នាំញ៉ាំឲ្យសរ ថ្នាំបណ្តុះសក់ និងមានរបស់ផ្សេងៗជាច្រើនទៀតដែលអ្នកស្រីដាក់លក់នៅក្នុងផ្ទះផង និងនៅOnlineផង។

ម្ចាស់ហាងដែលមានឈ្មោះថា កុសល វីយ៉ាដា (kosalViyada) ក្នុងគណនីហ្វេសបុក បានបន្តថា "ការលក់បែបនេះគឺវាចំណេញច្រើនគួរសម ហើយអ្នកដែលបញ្ជាទិញគឺមិនតថ្លៃទេ ដឹងតែឆាតប្រាប់ថា យករបស់នេះ ឬរបស់នោះហើយដាក់លេខទូរស័ព្ទឲ្យ ហើយខាងយើងយកឲ្យដល់កន្លែងនោះនឹងទទួលបានលុយភ្លាមៗ មិនសូវជាស៊ាំញ៉ាំដូចលក់ក្នុងហាងឡើយ"។

អ្នកស្រីបន្តថា សម័យនេះគឺជាសម័យដែលយុវវ័យចង់ស្អាត ដូចនេះអតិថិជនគឺស្ទើរតែ១០០%ជាយុវជន។

ដូចគ្នានេះដែរ អ្នកដែលធ្វើការផ្សព្វផ្សាយផលិតផលតាមរយៈអនឡាញមួយរូបទៀត ក៏បានបង្ហាញអំពីកំណើននិងប្រជាប្រិយភាពនៃការធ្វើទីផ្សារផលិតផលរបស់ខ្លួនតាមរយៈអនឡាញនេះផងដែរ។

អ្នកស្រី កែវលក្ខណា ដែលជាអាជីវករវ័យ២៥ឆ្នាំ ក៏ជាអ្នកលក់ និងផ្សព្វផ្សាយទីផ្សារផលិតផលអ្នកស្រីតាមអនឡាញម្នាក់ដែរបានឲ្យដឹងថា សម័យនេះគឺវាទូលំទូលាយហើយងាយស្រួល ជាពិសេស គឺការប្រើប្រាស់ជាមួយនឹងប្រព័ន្ធអ៊ីនធឺណេត។

អ្នកស្រីបានបន្តទៀតថា ដោយសារមិនចង់ឲ្យការប្រើប្រាស់ប្រព័ន្ធនេះ អត់ប្រយោជន៍ អ្នកស្រីក៏បានចាប់យករបរផ្សព្វផ្សាយតាមអនឡាញនេះព្រោះវាមិនចាំបាច់ចំណាយពេលវេលាច្រើន ក្នុងការរៀបចំទុកដាក់ ឬមានទីកន្លែងអ្វីជាធំដុំនោះទេ គ្រាន់តែប្រកាសតាមហ្វេសប៊ុកពីផលិតផលដែលយើងលក់មានអីខ្លះតម្លៃនិងលេខទូរស័ព្ទយើង ហើយជា ពិសេសឆ្លើយតបរាល់សំណួរផ្សេងៗដែលអតិថិជនសួរគឺបានហើយ។

អ្នកស្រីលក្ខណានិយាយប្រាប់ថា "វាពិតជាលក់ដាច់ខ្លាំងមែនទែន ពេលខ្លះខ្ញុំស្ទើរតែដឹកឲ្យគេមិនចង់ទាន់ផងព្រោះមានការបញ្ជាទិញច្រើនពីយុវជន"។

ជុំវិញកំណើននភោពជាគជ័យតាមរយៈការធ្វើទីផ្សារតាម បច្ចេកវិទ្យាព័ត៌មាននេះ កញ្ញា សុភាដែលគេដឹងថា កំពុងបម្រើការងារក្នុងទីក្រុងភ្នំពេញហើយក៏ជាអ្នកដែលចូលចិត្តទិញទំនិញ របស់តាមអនឡាញនេះបានឲ្យដឹងថា នាងចូលចិត្តទិញតាមវិធីនេះ ដោយសារវាមានភាពងាយស្រួលដល់ខ្លួនដែលមានភាពមមារញឹកជាមួយនឹងការងារ។

សុភាបញ្ជាក់ថា "ពេលខ្លះយើងគ្រាន់តែ ឆាតទៅប្រាប់ថាទិញរបស់អ្វី ហើយសួរតម្លៃ និងព័ត៌មានខ្លះៗអំពីផលិតផលដែលយើងចង់ទិញនោះ ហើយប្រាប់ថាយកពេលណានោះអ្វីដែលយើងត្រូវការនិងបានតាមភ្លាមៗដោយមិនចាំបាច់ដើរផ្សារឲ្យខាតពេល"។

កញ្ញាបានបន្តទៀតថា "ខ្ញុំភាគច្រើនបើកហ្វេសបុក ដូចនេះពេលឃើញផលិតផលផ្សេងៗ ឬសម្លៀកបំពាក់ដែលស្អាតៗ ហើយពេញចិត្ត គឺឆាតទៅកាម៉ង់តែម្តងទោះបីជាវារាងថ្លៃហើយមិនអាចតថ្លៃបានក៏ដោយ"។

លោកងិន ចម្រើន ក៏បានឲ្យដឹងផងដែរថា ការទិញតាមអនឡាញនេះគឺវាមានភាពងាយស្រួលម៉្យាងសម្រាប់យើងដោយសារតែម្នាក់ៗរវល់ជាមួយនឹងការងារដែលគ្មានពេលវេលាច្រើនក្នុងការដើរផ្សារដើម្បីទិញរបស់ទាំងនោះទេ។

លោកបន្តទៀតថា សម័យនេះគឺជាសម័យទំនើបហេតុនេះ វាគ្រាន់តែកាន់ទូរស័ព្ទ ហើយបើកមើលផលិតផលជាច្រើនមុខដែលគេបង្ហោះតាមបណ្តាញសង្គម នោះវាធ្វើឲ្យយើងចាប់អារម្មណ៍ព្រោះម៉ូតម៉ាកស្អាតៗ ហើយណាមួយតម្លៃក៏មិនសូវជាខុសគ្នាពីហាងខាងក្រៅដែរ បើគិតទាំងការធ្វើដំណើរនិងថ្លៃផ្ញើកង់ម៉ូតូទៀតនោះ។

ចម្រើន ក៏បានបញ្ជាក់អំពីបញ្ហាផងដែរថា ពេលខ្លះការទិញតាមអនឡាញនេះមានការបោកប្រាស់ដែរដូចជា ចម្លងផលិតផល ឬម៉ូតម៉ាកផ្សេងៗដោយសំអាងថា ល្អដូចក្រុមហ៊ុនពិតៗក្រោយពេលដែលយើងទិញយកមកប្រើទើបយើងដឹងថា វាជារបស់ក្លែងក្លាយ ព្រោះតែយើងមិនបានទៅពិនិត្យដោយផ្ទាល់។

បច្ចុប្បន្នយើងដឹងថា អនឡាញគឺជាមធ្យោបាយ ឬក៏ជាវិធីសាស្ត្រនៅក្នុងការធ្វើធុរកិច្ចមួយនៅកម្ពុជា ខណៈដែលស្ថិតិនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានៅកម្ពុជាមានកំណើនគួរឲ្យកត់សម្គាល់។

យោងទៅតាមស្ថិតិមួយដែលកំណត់នៅក្នុងរបាយការណ៍នៃស្ថិតិឌីជីថលកម្ពុជាបានឲ្យដឹងថា រហូតមកដល់ពេលនេះចំនួនអ្នកប្រើប្រាស់បណ្តាញអ៊ីនធើណេតមានប្រមាណជា ៥ លាននាក់ ខណៈដែលចំនួនចុះបញ្ជីប្រើប្រាស់ទូរស័ព្ទដៃមានរហូតដល់ទៅ ២៥ លាននាក់។

ប្រភពដដែលបានបន្តថា នៅក្នុងចំណោមនោះ អ្នកដែលនិយមលេង និងចាប់អារម្មណ៍លើប្រព័ន្ធបច្ចេកវិទ្យាមានរហូតដល់ទៅ ២,៦ លាននាក់ អ្នកលេងហ្គេមអនឡាញមាន ១,៩លាននាក់ អ្នកស្តាប់តន្ត្រីនិងចម្រៀងមាន ២ លាននាក់ អាហារមាន ១,៧ លាននាក់។

ប្រភពដដែលបានបន្តថា ចំនួនអ្នកប្រើប្រាស់ និងលេងបណ្តាញសង្គម ជាពិសេស គឺហ្វេសបុកនេះ គឺមានចំនួនប្រមាណជា ៣,៤លាននាក់ នៅក្នុងនោះអ្នកដែលពេញវ័យ ដែលមានអាយុ ពី ១៨ ដល់២៤ឆ្នាំ គឺជាអ្នកលេងហ្វេសបុកសកម្មជាងគេ។ តួលេខបានបង្ហាញថា អ្នកដែលលេងហ្វេសបុក ប្រមាណជា ៩៧០.០០០នាក់ គឺបានចូលរៀននៅកម្រិតមហាវិទ្យាល័យ ខណៈដែល លេងហ្វេសបុក ចំនួន ៩៩.០០០នាក់ផ្សេងទៀត គឺមានមុខជំនាញ ខាងរដ្ឋបាលហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ។*ដោយ ស្រីម៉ាច*

# ការបំពុលខ្យល់នៅទីក្រុងបង្កើនហានិភ័យនៃជំងឺទឹកនោមផ្អែមប្រភេទទីពីរ


ថតដោយសាហការី ស៊ីអេសស៊ី

ថ្មីៗនេះ ក្រុមអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលហេមហូល សិនទ្រុម មុនចិន និងនៅមជ្ឈមណ្ឌលអាឡឺម៉ង់នៃការស្រាវជ្រាវលើសុខភាពបរិស្ថាន បានប៉ាន់ប្រមាណនៅក្នុងការសិក្សាមួយថា ការបំពុលបរិយាកាសនៅទីក្រុង អាចបង្កើនហានិភ័យផងដែរក្នុងការសាយភាពជំងឺទឹកនោមផ្អែមប្រភេទទីពីរ ដោយបង្អាក់ការបញ្ចេញសារជាតុអាំងស៊ុយលីន ពោលគឺវាមានគ្រោះថ្នាក់ស្មើនឹងការបម្រែបម្រួលហ្សែន ឬទម្លាប់មិនល្អនៅក្នុងការរស់នៅ។ ជំងឺទឹកនោមផ្អែមប្រភេទទី២ តែងកើតឡើងចំពោះមនុស្សដែលមានវ័យចំណាស់ចាប់ពីអាយុ ៤៥ឆ្នាំឡើងទៅ និងអ្នកដែលលើសទម្ងន់។

ក្រុមអ្នកស្រាវជ្រាវបានធ្វើការវិភាគលើទិន្នន័យវេជ្ជសាស្ត្រ លើមនុស្ស ៣០០០ នាក់ ដែលរស់នៅក្នុងទីក្រុង និងតំបន់ជនបទពីរដែលនៅក្បែរខាងទីក្រុង។ អ្នកចូលរួមត្រូវបានគេសម្ភាសន៍អំពីសុខភាពរបស់ពួកគេ និងត្រូវបានត្រួតពិនិត្យសភាពរាងកាយ និងការរស់នៅរបស់ពួកគេ។

គំរូឈាមដំបូងត្រូវបានដកយកពីម្នាក់ៗក្នុងចំណោមពួកគេដើម្បីរកឲ្យឃើញនូវសម្គាល់ជីវសាស្ត្រនៃការបង្អាក់ នៃការផលិតជាងអាំងស៊ុយលីន ដែលជាអ័រមូនធម្មជាតិដែលត្រូវបញ្ចេញដោយលំពែង និងមានតួនាទីដឹកជញ្ជូនជាតិគ្លុយកូស (ស្ករ) ចូលទៅក្នុងកោសិកានៃសារពាង្គកាយ។ បន្ទាប់មកទិន្នន័យឈាមទាំងនេះត្រូវបានប្រៀបធៀបទៅនឹងការប្រមូលផ្តុំជាតិពុលនៃបរិយាកាស (ឧស្ម័នកាបូនិច និងធូលី) នៅទីកន្លែងស្នាក់នៅរបស់អ្នកចូលរួមដកពិសោធន៍។

លទ្ធផលបង្ហាញថា អ្នកដែលមានការខូចខាតនៃដំណើរការប្រែសារជាតុគ្លុយកូសក្នុងរាងកាយ ដែលនឹងយើងអាចឈានដល់កើតជំងឺទឹកនោមផ្អែម ដោយការរងឥទ្ធិពលនៃការបំពុលក្នុងបរិយាកាស។ លោកវេជ្ជបណ្ឌិតកាទ្រីន វល ជាអ្នកសិក្សាស្រាវជ្រាវបានគូសបញ្ជាក់ថា "ការចងភ្ជាប់រវាងការកើនឡើងនៃសញ្ញាសម្គាល់នៃជំងឺទឹកនោមផ្អែមក្នុងឈាម និងការកើនឡើងនៃការបំពុលបរិយាកាស គឺមានសភាពគួរឲ្យចាប់អារម្មណ៍ជាពិសេស"។ ដូច្នេះក្នុងរយៈពេលវែង ការបំពុលបរិយាកាស គឺជាកត្តានៃហានិភ័យសម្រាប់ជំងឺទឹកនោមផ្អែមប្រភេទទីពីរ ជាពិសេសសម្រាប់អ្នកដែលមានដំណើរការមិនស្រួលនៃសារជាតុគ្លុយកូស (ស្ករ) នៅក្នុងឈាម។

ហើយបើយោងតាមសមាគមសុខភាពបរិស្ថានរបស់ប្រទេសបារាំង ការបំពុលនៅតាមផ្លូវថ្នល់អាចបង្កឲ្យមាននូវជំងឺទឹកនោមផ្អែម។ ហើយស្ត្រីដែលមានផ្ទៃពោះដែលទទួលរងការបំពុលពីផ្លូវថ្នល់អាចផ្តល់កំណើតដល់កូនមានមាឌមិនគ្រប់លក្ខណៈ។ ទារកមានទំងន់មិនគ្រប់គ្រាន់នៅពេលចាប់កំណើត តិចជាង២,៥ គីឡូក្រាម គឺមានទាក់ទងទៅនឹងបញ្ហាផ្លូវដង្ហើម និងជំងឺផ្សេងៗទៀតនៅរយៈពេលក្រោយមកនៅក្នុងជីវិត មានដូចជាជំងឺទឹកនោមផ្អែមជាដើម។

ដូច្នេះការរស់នៅត្រូវតែមានតុល្យភាពដោយប្រកាន់ការបរិភោគចំណីអាហារឲ្យបានត្រឹមត្រូវ ការគេងគ្រប់គ្រាន់ និងការធ្វើឲ្យមានសកម្មភាពគឺអាចជួយឲ្យយើងមានសុខភាពល្អ បន្ថយគ្រោះថ្នាក់នៃជំងឺទឹកនោមផ្អែម និងជំងឺដង្កាត់ធ្ងន់ធ្ងរដទទៀត។

*ដោយ ផាត សំភី*

# បង្កាជំងឺសារទឹក

ជំងឺសារទឹកបង្កឡើងដោយបាក់តេរីឈ្មោះប៉ាស្ទ័រ៉េល ឡា មុលតូស៊ីដា ប្រភេទបេ (Pasteurella Multocida Type B)។ បាក់តេរីប្រភេទនេះបង្កឡើងតែនៅលើសត្វគោក្របី។ ពួកវារស់នៅ និងបំបែកខ្លួននៅក្នុងដើមក។ សត្វគោខ្លះមានផ្ទុកមេរោគនៃជំងឺតែវាមិនឈឺទេ។ សភាពជំងឺកើតឡើងអាស្រ័យទៅលើសភាពស្ត្រេស៍របស់សត្វគោ។ ជំងឺនេះផ្ទុះឡើងនៃស្ថានភាពកន្លែងនៅសើម ដែលប្រឈមនឹងការសាយភាយជំងឺខ្លាំង។ ហ្វូងសត្វប្រមូលផ្តុំគ្នាច្រើនរួមជាមួយអាកាសធាតុសើម ជាពិសេសនៅរដូវភ្លៀង ដែលជាសកម្មភាពនៃការសាយភាយជំងឺ។

គោចាប់ផ្តើមឈឺចាប់ពី ២-៣ម៉ោង ក្រោយពីបាក់តេរីជ្រាបចូលទៅក្នុងខ្លួនវា។ គោអាចងាប់ពីក្រោយពេលមានជំងឺនេះក្នុងរយៈពេលប្រមាណពី ៦-២៤ ម៉ោង។

រោគសញ្ញានៃជំងឺសារទឹក មានដូចជាគោមិនចង់ដើរ គ្រុនក្តៅខ្លាំង ហូរទឹកមាត់ និងសម្បោរ ពិបាកដកដង្ហើម មានឈាមតាមច្រមុះ ហើមនៅក្បាល ក និងទ្រូង។ ការឆ្លងជំងឺគឺតាមរយៈដោយផ្ទាល់ និងដោយប្រយោល។ ក្រោយពេលគោងាប់ បើសិនជាគេធ្វើការវះកាត់នៅកន្លែងដែលហើមនោះ វានឹងបង្ហាញឲ្យឃើញមានដុំឈាមកក និងមានទឹកនៅក្នុងស្រោមបេះដូង ទ្រូង និងពោះ។

ដោយជំងឺសារទឹកមានការវិវត្តលឿន វាធ្វើឲ្យមានការលំបាកក្នុងការព្យាបាលទាន់ពេល។ កសិករត្រូវចាក់សុយហ្វាណាមីត និងតេត្រាស៊ីគ្លីន តាមសរសៃវ៉ែន ឬកសិករអាចទៅរកបសុពេទ្យដើម្បីចាក់ឲ្យក៏បាន។ កសិករត្រូវចាក់វ៉ាក់សាំងដើម្បីការពារជំងឺសារទឹកនៅរៀងរាល់ ៦ខែ ម្តង ជាពិសេសនៅមុនរដូវភ្លៀង។ ដើម្បីឲ្យមានភាពស៊ាំដល់កូនដែលទើបនឹងកើត កសិករត្រូវចាក់វ៉ាក់សាំងដល់មេផើមនៅដំណាក់កាលចុងក្រោយនៃការផើមរបស់វា។

គោ គឺជាសត្វមានប្រយោជន៍ច្រើនចំពោះ ប្រជាកសិករសម្រាប់ប្រើជាកម្លាំងអូសទាញផ្តល់សាច់ និងទឹកដោះសម្រាប់លក់យកកម្រៃ។ ដូច្នេះដើម្បីចិញ្ចឹមគោឲ្យមានទិន្នផលខ្ពស់ ក្រៅពីការជ្រើសរើសពូជ និងការផ្តល់ចំណី ការធ្វើអនាម័យ ការការពារ និងព្យាបាលជំងឺ ក៏មានសារៈសំខាន់ផងដែរ។

ដើម្បីការពារជំងឺដង្កាត់ផ្សេងៗកសិករត្រូវធ្វើអនាម័យគោ ដោយធ្វើអនាម័យទាំងកន្លែងរស់នៅ ខ្លួនគោ និងអនាម័យចំណីអាហាររបស់វា។ កន្លែងរស់នៅ និងដេករបស់គោ កសិករត្រូវសំអាតឲ្យបានស្អាត និងមិនមានភក់ជ្រាំ។ កសិករត្រូវកើបលាមកគោឲ្យបានញឹកញាប់យ៉ាងហោចណាស់ឲ្យបាន ១-២ដងក្នុងមួយថ្ងៃ និងត្រូវលាងសម្អាតខ្លួនគោឲ្យបានញឹកញាប់ជាពិសេសនៅរដូវក្តៅ។ គោត្រូវការផឹកទឹកស្អាតច្រើនជារៀងរាល់ថ្ងៃ ឲ្យគោផឹកមុនពេលផ្តល់ចំណី យ៉ាងតិចបីដងក្នុងមួយថ្ងៃ។ កសិករមិនត្រូវឲ្យគោជាន់ក្នុងស្នូកទឹក និងចំណីនោះទេ ពីព្រោះវាអាចឆ្លងនូវជំងឺ។

*ដោយ ផាត សំភី*


ថតដោយ រិទ្ធី

# ២៥ឆ្នាំក្រោយកិច្ចព្រមព្រៀងសន្តិភាពកម្ពុជាហាក់ដូចជាមិនទាន់ឯកភាពគ្នាខាងមតិនិងទស្សនៈ



*រូបថតពីហ្វេសបុក សម្តេចតេជោ ហ៊ុន សែន*

ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ មកដល់ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៦ ជាថ្ងៃខួប ២៥ឆ្នាំ នៃការចុះហត្ថលេខាលើកិច្ចព្រម ព្រៀងទីក្រុងប៉ារីស ស្តីពីសន្តិភាពនៅ ប្រទេសកម្ពុជា ក៏ប៉ុន្តែ២៥ ឆ្នាំនេះកម្ពុជា នៅតែមានការយល់ឃើញខុសគ្នា ទៅលើ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយនេះ។

កិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃ២៣ ខែតុលា ឆ្នាំ១៩៩១ ត្រូវបានចុះហត្ថលេខា ដោយភាគីជម្លោះខ្មែរទាំង ៤ក្រុម គឺ ក្រុមសីហនុនិយម ក្រុមអ្នកជាតិនិយម របស់លោក សឺន សាន ក្រុមខ្មែរក្រហម របស់ ប៉ុល ពត និងរដ្ឋកម្ពុជារបស់សម្តេច តេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន និង អង្គការសហប្រជាជាតិ ប្រមុខការទូតនៃ ប្រទេសចំនួន ១៨ ដែលរួមមានជាពិសេស គឺឥណ្ឌូនេស៊ី និងបារាំង។ កិច្ចព្រមព្រៀង នេះ មានគោលដៅសំខាន់ៗ បីយ៉ាង ដោយទី១ គឺរៀបចំឲ្យមានសន្តិភាពឡើង វិញនៅប្រទេសកម្ពុជា តាមរយៈការអនុវត្តន៍កិច្ចឈប់បាញ់ និងការរំសាយអាវុធ នៅក្នុងជួរកងទ័ពនៃភាគីជម្លោះនៅកម្ពុជា ទាំងអស់ ដោយឡែកគោលដៅទី២ គឺចាក់ គ្រឹះលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេស កម្ពុជា តាមរយៈការរៀបចំបោះឆ្នោតសភា ធម្មនុញ្ញ រីឯចំណុច ទី៣ គឺការពារអធិបតេយ្យ ឯករាជ្យបូរណភាព និងភាពពុំអាច រំលោភបំពានបានឡើយនូវទឹកដីអព្យាក្រឹត ភាព និងឯកភាពជាតិរបស់ប្រទេសកម្ពុជា។

ចំណុចទាំងបីនេះ គឺបើតាមទស្សនៈ យើងខ្ញុំ គឺបានសម្រេចសឹងតែ ទាំងអស់ ទៅហើយ ជាពិសេសគឺ ចំណុចទី១ និង ចំណុចទី៣ ប៉ុន្តែអ្វីដែលជាបញ្ហានៅ ប្រទាំងប្រទើសនោះ គឺទាក់ទងនឹងចំណុច ទីពីរ គឺការចាក់គ្រឹះលទ្ធិប្រជាធិបតេយ្យ។

កិច្ចព្រមព្រៀងសន្តិភាពនេះ គឺមាន ចតុភាគី ប៉ុន្តែនៅពេលនេះ ត្រីភាគីហាក់ ដូចជារលាយបាត់រូបទៅហើយ គឺមាន ក្រុមខ្មែរក្រហម ក្រោយសមាហរណកម្ម ក្នុងរង្វង់១៩៩៧ និង១៩៩៨ ក្រុមអ្នក ជាតិនិយមរបស់លោក សឺន សាន ក្រោយមរណៈភាពរបស់លោក ដោយ ឡែកក្រុមអ្នកសីហនុនិយម ដែលគដឹង ថា ហ្វុនស៊ីនប៉ិចនោះ គឺកំពុងតែជួបនៅ វិបត្តិក្រោយពី បរាជ័យនៅក្នុងការបោះឆ្នោតជាបន្តបន្ទាប់។

សព្វថ្ងៃនេះ អ្នកដែលនៅតែរំលឹកអំពី កិច្ចព្រមព្រៀងសន្តិភាពនេះ គឺនៅមាន តែបីក្រុម ដោយមួយក្រុមគឺ គណបក្ស ប្រជាជនកម្ពុជា ដែលជាសមាជិកនៃចតុភាគី និងជាស្ថាបនិកដ៏ចំបងនៃកិច្ចព្រម ព្រៀងនេះ គណបក្សសង្គ្រោះជាតិ ដែល ជាគណបក្សប្រឆាំង និងសង្គមស៊ីវិលនិង អ្នកជំនាញការបរទេស។

សម្តេចតេជោ ហ៊ុន សែន នៅតែរំលឹក នឹងចងចាំនៅថ្ងៃជាប្រវត្តិសាស្ត្រនេះ ដោយ ចំថ្ងៃនោះ បានបង្ហោះរូបថតអនុស្សាវរីយ មួយចំនួនអំពីកិច្ចចរចាររវាង អតីតព្រះមហាវីរក្សត្រ សម្តេចព្រះ នរោត្តម សីហនុ ប៉ុន្តែទោះបីជាយ៉ាងណាសម្តេចមិនសង្កត់ និងផ្តល់តម្លៃធំដល់ថ្ងៃនោះទេ។ អ្វីដែល សម្តេចបានសង្កត់នោះ គឺការចរចាថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ ដែលហៅថា ការចរចា សីហនុ-ហ៊ុន សែន។ សម្តេចបាន ឲ្យតម្លៃ ទៅលើខ្មែរ នៅក្នុងការបញ្ចប់សង្គ្រាម និង នាំសន្តិភាពនៅកម្ពុជា។ សម្តេចតេជោ សង្កត់ធ្ងន់ថា អ៊ុនតាក់បានប្រើប្រាស់ថវិកា អស់ជាង ២.០០០លានដុល្លារ ប៉ុន្តែកម្ពុជា នៅតែតំបន់ត្រួតត្រាពីរ រហូតដល់មាន នយោបាយឈ្នះឈ្នះ ទើបកម្ពុជាមាន សន្តិភាព។

នាថ្ងៃគម្រប់ខួប ២៥ឆ្នាំ ខាងសង្គម ស៊ីវិល និងគណបក្សប្រឆាំងវិញ បាន សម្តែងមតិថា ស្ថានភាពប្រជាធិបតេយ្យ និងបរិយាកាសសិទ្ធិមនុស្ស គឺកំពុងតែតាន តឹង ខណៈដែលពេលនេះ មានមន្ត្រីនៃអង្គការសង្គម ស៊ីវិល និងគណបក្សប្រឆាំង មួយចំនួនត្រូវបានគេប្រើប្រាស់តុលាការ ដើម្បីអនុវត្តច្បាប់ បំបិទសិទ្ធិ និងគំរាម កំហែងសង្គមស៊ីវិល សកម្មជន មេដឹកនាំ សហគមន៍ ពលរដ្ឋ និងបក្សប្រឆាំង។

រហូតមកដល់ពេលនេះ មានមន្ត្រីគណបក្សប្រឆាំង សមាជិកសភា និងព្រឹទ្ធសភា គណបក្សប្រឆាំង ជាច្រើនរូបដោយរួមទាំង មន្ត្រីនៃអង្គការសិទ្ធិមនុស្ស មួយចំនួន កំពុង តែជាប់ឃុំឃាំងនៅពន្ធនាគារ ក្រោមបទ ចោទប្រកាន់ផ្សេងៗ ដែលពួកគេបានអះ អាងថា ជាការបំបិទសិទ្ធិបញ្ចេញមតិ។

*ដោយ អរិយបុត្រ*

# ព័ត៌មានអំពីការវិលត្រឡប់របស់ប្រធានគណបក្សប្រឆាំងក្លាយជាព័ត៌មានសំខាន់ប្រចាំសប្តាហ៍

ក្រោយពី លោក សម រង្ស៊ី ប្រធាន គណបក្សប្រឆាំងដែលកំពុងតែនិរទេស ខ្លួននៅបរទេស ប្រកាសអំពីការវិលត្រឡប់ មកប្រទេសកម្ពុជាវិញ កាលពីថ្ងៃទី១៩ តុលា ២០១៦ មកដំណឹងនេះបានក្លាយ ជា ព័ត៌មានសំខាន់នៅលើប្រព័ន្ធផ្សព្វផ្សាយ នៅកម្ពុជាទាំងកាសែតភាសាជាតិ និង ភាសាបរទេស វិទ្យុ និងទូរទស្សន៍នានា នៅកម្ពុជា។

នៅថ្ងៃនេះលោក សម រង្ស៊ី បានបង្ហោះ នូវសារដ៏ខ្លីមួយថា លោកនឹងវិលត្រឡប់ មកកម្ពុជា ប៉ុន្តែទោះបីជាយ៉ាងណាក៏ ដោយ សាររបស់លោកមិនបានបញ្ជាក់ឲ្យ ច្បាស់ថា លោកនឹងវិលត្រឡប់មកកម្ពុជា វិញនៅក្នុងពេលថ្ងៃណាឲ្យប្រាកដនោះទេ។

បន្ទាប់ពីសារនោះ បានចេញផ្សាយ លោក សម រង្ស៊ី បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយ មួយចំនួន ថា លោក អាចនឹងត្រឡប់មក កម្ពុជាវិញ តាមគ្រប់មធ្យោបាយ នៅមុន ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាឆ្នាំ២០១៧ ខាងមុខនេះ ។

បន្ទាប់ពីសេចក្តីប្រកាសនោះចេញ ក៏ មានការបែកធ្លាយនូវព័ត៌មាន ដែលមន្ត្រី ជាន់ខ្ពស់ថ្នាក់រដ្ឋលេខាធិកាមួយរូបនៅ ទីស្តីការគណរដ្ឋមន្ត្រី បានចេញទៅកាន់ បណ្តាក្រុមហ៊ុនអាកាសចរណ៍នានា ដែល ហោះត្រង់ចូលកម្ពុជា ។

លិខិតនោះបានបញ្ជាឲ្យគ្រប់ក្រុមហ៊ុន អាកាសចរណ៍ទាំងអស់ ដែលធ្វើប្រតិបត្តិ ការហោះហើរមកកម្ពុជា មិនឲ្យលោក សម រង្ស៊ី ឡើងលើយន្តហោះមកកម្ពុជា ទេ និងត្រូវផ្តល់របាយការណ៍ឲ្យបានទៀង ទាត់ក្នុងករណីលោក សម រង្ស៊ី បាន ព្យាយាមទិញសំបុត្រមកកម្ពុជា។ ប្រភព ដដែលបានបន្តថា ក្នុងករណីលោក សម រង្ស៊ី ធ្វើដំណើរមកកម្ពុជា តាមយន្ត ហោះណាមួយ យន្តហោះនោះត្រូវបង្វែរ ទិសដៅទៅអាកាសយានដ្ឋានដើមវិញ ដោយមិនអនុញ្ញាតឲ្យចុះចតឡើយ។ លិខិតក៏បានបន្តថា ក្នុងករណីលោក សម រង្ស៊ី នៅតែអាចចុះដល់អាកាសយាន ដ្ឋានណាមួយនៅកម្ពុជា បានក៏មិនត្រូវឲ្យ ចាកចេញពីយន្តហោះឡើយ និងត្រូវ ត្រឡប់ទៅអាកាសយានដ្ឋានដើមវិញ។ ហើយក្នុងករណីលោក សម រង្ស៊ី ចាក ចេញពីយន្តហោះ នគរបាលអន្តោប្រវេសន៍ ត្រូវចាត់វិធានការផ្លូវច្បាប់កុំឲ្យចូលកម្ពុជា បាន និងត្រូវចាត់វិធានការផ្សេងៗតាមការ ចាំបាច់។ បន្ទាប់ពីការបែកធ្លាយនូវព័ត៌មានទាំងពីរនេះ ក៏មានអត្ថបទព័ត៌មានក្តៅ អត្ថបទបែបវិភាគ អត្ថបទជាសម្រង់ទស្សនៈ និងមតិ និងបទវិចារណៈកថា មួយចំនួន បានចេញផ្សាយនៅលើបណ្តាញផ្សព្វផ្សាយ នៅកម្ពុជាជាបន្តបន្ទាប់ថែមទៀត ដោយ បញ្ចេញមតិទៅតាមគោលជំហរនយោបាយ គោលជំហរ បុគ្គល និងលក្ខណខណ្ឌច្បាប់ នានា នៅកម្ពុជាធ្វើជាទឡ្ហីករណ៍រៀងៗ ខ្លួន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ នៅមិនទាន់មានព័ត៌មានអំពីកាលបរិច្ឆេទ ដែលប្រធានគណបក្សសង្គ្រោះជាតិ នឹង វិលមកវិញ ឲ្យប្រាកដនៅឡើយទេ។

*ដោយ អរិយបុត្រ*

# កម្មករនិងម្ចាស់រោងចក្រហាក់មិនសូវរីករាយនឹងបញ្ហាប្រាក់បៀវត្សប្រចាំខែនៅឆ្នាំ២០១៧

ក្រសួងការងារបានប្រកាសកាលពីចុងខែកញ្ញាថា ប្រាក់ឈ្នួលកម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងនឹងទទួលការតម្លើងប្រាក់ឈ្នួលអប្បបរមានៅក្នុងម្នាក់១៥៣ដុល្លានៅក្នុង១ខែ។

ចំពោះការសម្រេចនេះ គឺបានទទួលទាំងការស្វាគមន៍ និងការស្ទាក់ស្ទើរពីកម្មករ និងកម្មការនីដោយសារតែពួកគេបារម្ភរឿងអតិផរណានៃតម្លៃទំនិញនៅលើទីផ្សារនៅក្នុងប្រទេសខណៈដែលតំណាងភាគីម្ចាស់រោងចក្រក៏ហាក់ដូចជាមិនជាសូវរីករាយ នឹងការតម្លើងនេះផងដែរ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានថ្លែងថា នេះគឺជាការសម្រេចមួយ ដែលឆ្លងកាត់កិច្ចប្រជុំជាច្រើនភាគីនិងជាច្រើនដង ទម្រាំឈានដល់ការសម្រេចបែបនេះ។

លោកបានបញ្ជាក់ថា តាមស្មារតីនៃកិច្ចប្រជុំថ្ងៃទី២៩ ខែកញ្ញា ការដំឡើងប្រាក់ឈ្នួលនោះ គឺធ្វើឡើងតាមរយៈការបោះឆ្នោតលើតួលេខចំនួន៣ ដោយភាគីរដ្ឋាភិបាលស្នើ ១៤៨ដុល្លារ ហើយភាគីសហជីពបានស្នើ ១៧១ដុល្លារ ដោយឡែកតំណាងថៅកែរោងចក្រ គឺស្នើត្រឹមតែ ១៤៧ដុល្លារប៉ុណ្ណោះ។

លោករដ្ឋមន្ត្រីបានបន្តថា លទ្ធផលបង្ហាញថា ទឹកប្រាក់ ១៤៨ដុល្លារ ដែលស្នើដោយភាគីរដ្ឋាភិបាល ទទួលបានការគាំទ្រចំនួន ២២សំឡេង។ ចំណែក ១៧១ ដុល្លារស្នើ ដោយភាគីសហជីពមានសំឡេងគាំទ្រ ២ សំឡេង និង១៤៧ដុល្លាររបស់ថៅកែរោងចក្រ គឺគ្មានការគាំទ្រ។

លោករដ្ឋមន្ត្រីបានបន្តទៀតថា តាមស្មារតីនេះរាជរដ្ឋាភិបាលកម្ពុជាក៏បានសម្រេចយក១៤៨ ដុល្លារ បូកបន្ថែមនឹងទឹកប្រាក់ឧបត្ថម្ភបន្ថែមពីខាងរាជរដ្ឋាភិបាល ៥ ដុល្លារទៀតគឺកម្មករ និងកម្មការនីម្នាក់ៗនឹងបានឡើងដល់ ១៥៣ដុល្លារ ហើយគោលនយោបាយតម្លើងប្រាក់ខែនេះនឹងដាក់ឲ្យអនុវត្ត គឺចាប់ពីខែមករា ឆ្នាំ២០១៧តទៅ។

បន្ទាប់ពីការសម្រេច និងការប្រកាសជាផ្លូវការ សហជីពកម្មករមួយចំនួន ហាក់ពេញចិត្ត ប៉ុន្តែសហជីពមួយចំនួន ហាក់ដូចជាមិនសូវពេញចិត្តខណៈដែលកម្មករក៏មានស្ថានភាពដូចគ្នានេះផងដែរ។

សម្ព័ន្ធសហជីពចលនាកម្មករ និងបណ្តាសហជីពមួយចំនួន ហាក់សំដែងការគាំទ្រ ចំពោះការប្រកាសតម្លើងប្រាក់បៀវត្សនៅឆ្នាំ២០១៧នេះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ហៅកាត់ថា ស៊ីខារវ៉ូ និងសម្ព័ន្ធសហជីពកម្ពុជា គឺប្រកាសពីការមិនពេញចិត្តនឹងការតម្លើងនេះទេ ដោយនៅតែទាមទារ ១៧១ ដុល្លារ ជាមួយនឹងការអះអាងថា ការសម្រេចនេះគឺមិនទាន់ឆ្លើយតបនឹងតម្រូវការរបស់កម្មករ ពោលគឺបើនិយាយអំពីប្រាក់បៀវត្សរ៍ និងតម្លៃទំនិញនៅលើទីផ្សារ គឺមិនតុល្យភាព ហើយបានស្នើសុំឲ្យរាជរដ្ឋាភិបាលបន្តគិតគូបន្ថែមពីជីវភាពដល់កម្មករថែមទៀត។

ជុំវិញការសម្រេចតាមរយៈការប្រជុំអំពីបញ្ហាប្រាក់បៀវត្សរ៍កម្មករ និងកម្មការនីរោងចក្រកាត់ដេរនេះ តំណាងភាគីថៅកែរោងចក្រវិញក៏ហាក់ដូចជា មិនសប្បាយចិត្តនឹងលទ្ធផលនេះដែរ ដោយអះអាងថា ការតម្លើងនេះ គឺហាក់ដូចជាខ្ពស់បន្តិច ដែលអាចប៉ះពាល់ដល់ការចំណាយ និងថវិការបស់វិនិយោគិននៅក្នុងប្រទេសបាន។

លោក កាំង មូនីកា អគ្គលេខាធិការរងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានមានប្រសាសន៍ប្រាប់អ្នកសារព័ត៌មានថា នេះជាឆន្ទានុសិទ្ធិរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចតាមស្មារតីនៃកិច្ចប្រជុំនោះ ប៉ុន្តែយើងមានការព្រួយបារម្ភពីការចំណាយរបស់ថៅកែរោងចក្រខណៈដែលការបញ្ជាទិញហាក់ដូចជា មានការធ្លាក់ចុះ ។

កញ្ញា ជេត ស្រីនាថ ជាកម្មការនីរោងចក្រកាត់ដេរ នៅស្ទួនឧស្សាហកម្មកាណាឌីយ៉ានៅផ្លូវវេងស្រេង បានឲ្យដឹងថា ទឹកប្រាក់ ១៥៣ដុល្លារនេះ គឺវាមិនច្រើនទេ។

កញ្ញាបានបន្តថា បើប្រៀបធៀបរវាងប្រាក់ខែរបស់នាងនាពេលបច្ចុប្បន្ននេះ និងនៅឆ្នាំ២០១៧ គឺបានឡើង១៣ ដុល្លារ ប៉ុន្តែវានៅមិនគ្រប់ដែលអាចឲ្យកញ្ញា និងកម្មករឯទៀតអាចគេចចេញពីការហូបបាយកញ្ចប់នៅក្នុងមួយកញ្ចប់ ១.០០០រៀល ទៅ១.៥០០រៀល រាល់ថ្ងៃបានឡើយ។

កញ្ញាបានបញ្ជាក់ថា "១៣ ដុល្លារ នេះ គឺអាចសម្រាលបានតិចតួច ប៉ុន្តែបើបាន ៣១ ដុល្លារ គឺប្រហែលជា អាចជួយថ្លៃម្ហូបបានគ្រាន់ ហើយខ្ញុំក៏អាចហូបបានឆ្ងាញ់បន្តិចដែរ"។

លោកស្រី ខេង សម្ផស្ស ជាកម្មការនីរោងចក្រកាត់ដេរ នៅម្តុំផ្លូវវេងស្រេងដែរនោះ បានបន្តថា តែឡើងប្រាក់ខែនរណាក៏សប្បាយចិត្តដែរទោះជាតិចក្តីច្រើនក្តី ប៉ុន្តែ បើបាន១៧១ ដូចជាសហជីបគេបានប្រាប់មែននោះ មិនដឹងជាសប្បាយចិត្តយ៉ាងណាទេ។

លោកស្រីបានបន្តទៀតថា ប្រសិនបើអាចទទួលបានប្រាក់ខែលើសឥឡូវ តែ ៣១ ដុល្លារ ដូចជា សហជីពគាត់ទាមទារនោះ គឺយើងអាចទប់ទល់ថ្លៃម្ហូបប្រចាំខែ បានប៉ុន្តែត្រឹម ១៣ ដុល្លារ គឺវាមិនខុសពីបច្ចុប្បន្នប៉ុន្មានឡើយ។

លោកស្រីបានបន្តទៀតថា នៅក្នុងនាមជាកម្មការនីរោងចក្រកាត់ដេរ និងមានស្វាមី ជាអ្នករត់រ៉ឺម៉ក ដូចលោកស្រីការចំណាយលើអាហារនៅក្នុងមួយថ្ងៃមិនដែលលើសពី ១០.០០០រៀលទេ។

លោកស្រីបានបញ្ជាក់ថា " ១០.០០០ រៀលនោះមិនមែនរាល់ថ្ងៃទេ គឺមួយខែបានតែម្តងទៅ ២ដងទេ ភាគច្រើនបំផុតនៅក្នុងមួយថ្ងៃៗ ខ្ញុំចាយលើថ្លៃម្ហូបត្រឹមតែ ៥០០០ទៅ ៦០០០រៀល ប៉ុណ្ណោះ ដោយឡែកអង្ករយកមកពីស្រុក"។

លោក ជា លីដេ ដែលជាស្វាមី លោកស្រី ខេង សម្ផស្ស បានបន្ថែមថា ទឹកប្រាក់តម្លើង ១៣ដុល្លារនេះ វាមិនច្រើនទេ នៅពេលបច្ចុប្បន្ននេះ ដោយសារតែលោកធ្លាប់ឃើញអ្នកមានខ្លះហុចប្រាក់នៅក្នុងទំហំទឹកប្រាក់បែបនេះ ឬច្រើន ជូននារីៗ ដែលបម្រើសេវាកំសាន្តនានានៅក្នុងទីក្រុងភ្នំពេញតែញឹក។

លោកបានបញ្ជាក់ថា "ទឹកប្រាក់ត្រឹម ១៣ ដុល្លារនេះ ខ្ញុំគិតថា មិនស្មើនឹងក្រចកជើងនៃការចំណាយរកការសប្បាយរបស់អ្នកមានលុយមួយចំនួនក្នុងមួយយប់ផង។ ពេលខ្លះខ្ញុំចាំម៉ូយ ខ្ញុំឃើញ បុរសអ្នកមានឡានទំនើបខ្លះហុចឲ្យនារីឡង់សេ ២០ ទៅ៣០ដុល្លារ ក៏មានដែរ"។

តាមតួលេខពីអង្គការពលកម្មអន្តរជាតិបានឲ្យដឹងថា វិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងនៅកម្ពុជាកំពុងតែផ្តល់ការងារធ្វើដល់ប្រជាពលរដ្ឋប្រមាណជា ជាង៧០០.០០០នាក់។

*ដោយ អរិយបុត្រ*




*ថតដោយសាហការី ស៊ីអេសស៊ី*

# សាលាអប់រំជំនឿសន្តយ៉ូស្ទីនបើកឆ្នាំសិក្សាថ្មីសម្រាប់និស្សិត ជំនាន់ទី៣



ថតដោយ សុធីរិទ្ធ

សាលាអប់រំជំនឿសន្តយ៉ូស្ទីន គឺជាសាលាអប់រំជំនឿមួយរបស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ កាលពីព្រឹកថ្ងៃសៅរ៍ ទី០៨ ខែតុលា កន្លងទៅនេះ បានបើកឆ្នាំសិក្សាថ្មីសម្រាប់ ២០១៦ - ២០១៧ សម្រាបជំនាន់ទី៣ ដោយមានការចូលរួមជាអធិបតីពីសំណាក់លោកអភិបាលអូលីវីយេ ឆ្មីតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោកសាស្ត្រាចារ្យ រួមនិងតំណាងនិស្សិតជំនាន់ទី១ និងទី២ ព្រមទាំងនិស្សិតជំនាន់ទី៣ នៃសាលាអប់រំជំនឿសន្តយ៉ូស្ទីន ប្រមាណជាង៦០នាក់ ។

ថ្លែងក្នុងពិធីនេះលោកអភិបាលបានមានប្រសាន៍ថា សាលាអប់រំជំនឿសន្តយ៉ូស្ទីន គឺជាសាលា ដ៏មានអាទិភាពមួយសម្រាប់បងប្អូនគ្រីស្តបរិស័ទកាតូលិក។ លោកបន្តថា យើងជាគ្រីស្តបរិស័ទគំរូពេលដែលយើងធ្វើគំរូ ដែលនាំឲ្យមនុស្សដទៃយកគំរូតាម។ សម្រាប់យើងជាគ្រីស្តបរិស័ទមានបេសកកម្ម និងតួនាទីដែលម្នាក់ៗបានទទួលពីព្រះជាម្ចាស់ នោះគឺត្រូវស្វែងយល់បន្ថែមទៀតនៅក្នុងជីវិតរបស់ខ្លួនជាគ្រីស្តបរិស័ទ និងការធ្វើគំរូ ព្រោះថាដើម្បីរីកចម្រើននៅក្នុងជីវិត យើងត្រូវការមានគំរូ បើយើងមានគំរូល្អ យើងរីកចម្រើនក្នុងរបៀបល្អ ។

លោកអភិបាលបន្ថែមបន្តថា យើងជាគ្រីស្តបរិស័ទ ម្នាក់ៗត្រូវមានការទទួលខុសត្រូវសម្រាប់ព្រះសហគមន៍របស់ខ្លួន គឺម្នាក់ៗជាគ្រីស្តទូត នាំដំណឹងល្អ សម្រាប់អ្នកឯទៀតៗ ហើយត្រូវស្វែងយល់កាន់តែច្បាស់ នូវរាល់បញ្ហានានានៅក្នុងសង្គមរបស់យើងផ្ទាល់ផង ។

លោកអភិបាលបានគូសបញ្ជាក់ថា សិក្សានៅក្នុងសាលាអប់រំជំនឿសន្តយ៉ូស្ទីន ជួយឲ្យម្នាក់ៗទទួលបានចំណេះដឹង ដ៏ស៊ីជម្រៅក្នុងជីវិតខាងវិញ្ញាណ គឺជីវិតនៃការអធិដ្ឋាន សម្រាប់គាំទ្រជីវិតរបស់យើងជាគ្រីស្តបរិស័ទ។ ការសិក្សានៅទីនេះជួយម្នាក់ឲ្យមានអំណរសប្បាយ នៅក្នុងការបង្កើតជីវិតជាក្រុម គឺការកសាងមិត្តភាព ទំនាក់ទំនងជាគ្នា ធ្វើការងារជាក្រុមរួមគ្នា និងជួយគ្នាទៅវិញទៅមក។

អ្នកស្រី ឱ រស្មី អាយុ៣៥ ឆ្នាំ មកពីព្រះសហគមន៍កាតូលិកបឹងទំពុន នៃមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង បានឲ្យដឹងថា មូលហេតុ ដែលនាំឲ្យអ្នកស្រីចាប់អារម្មណ៍ចូលរៀននៅក្នុងសាលាអប់រំជំនឿសន្តយ៉ូស្ទីននេះ គឺអ្នកស្រីចង់ស្វែងយល់ឲ្យកាន់តែច្បាស់អំពីព្រះគម្ពីរ និងចង់ពង្រឹងជំនឿរបស់ខ្លួនឲ្យកាន់តែរឹងមាំឡើងៗ។ មួយវិញទៀត គឺអ្នកស្រីចង់ចូលរួមបំរើព្រះសហគមន៍ និងចង់ស្គាល់ព្រះជាម្ចាស់ឲ្យកាន់តែច្បាស់ ហើយនិងចំណាយពេលវេលានៅឲ្យកាន់តែជិតស្និទ្ធជាមួយព្រះអង្គ ខាងផ្លូវវិញ្ញាណ។

អ្នកស្រីបន្តទៀតថា នឹងទទួលបាននូវចំណេះដឹងក៏ដូចជាបទពិសោធន៍ថ្មីៗ ឬក៏ដូចជាការចែករំលែក ដែលទាក់ទងទៅនិងអត្ថន័យក្នុងព្រះគម្ពីរ ដែលយើងអាចឆ្លុះបញ្ចាំងអំពីជីវិតផ្ទាល់ខ្លួននោះផងដែរ។

សូមបញ្ជាក់ថា សាលាអប់រំជំនឿសន្តយ៉ូស្ទីន បានរៀបចំឡើងតាំងពីឆ្នាំ២០១១ ដោយព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ នាពេលកន្លងមក សាលានេះទើបបានបញ្ចប់ការសិក្សាចំនួន២ជំនាន់មកហើយ។ សម្រាប់រយៈពេលសិក្សាក្នុងមួយជំនាន់ៗ គឺមានរយៈពេល២ឆ្នាំ។ និស្សិតនឹងសិក្សាលើមុខវិទ្យា គម្ពីរវិទ្យា ទេវវិទ្យា ប្រវត្តិវិទ្យា សីលធម៌ និងគោលលិទ្ធិរបស់ព្រះសហគមន៍កាតូលិក ព្រមទាំងសិក្សាស្វែងយល់អំពីអន្តរជំនឿពីសាសនានានាជាដើម។ សាលានេះរៀបចំបង្កើតឡើង ក្នុងគោលបំណងជួយពង្រឹងជំនឿបន្ថែមសម្រាប់បងប្អូនគ្រីស្តបរិស័ទកាតូលិក ដែលបានទទួលពិធីជ្រមុជទឹករួច ឲ្យចេះរួបរួមគ្នា ចែករំលែកបទពិសោធន៍នៃជំនឿជាមួយគ្នា រួមនិងការធ្វើកម្មសិក្សាស្វែងយល់អំពីជំនឿរបស់គ្រិស្តបរិស័ទនៅតាមបណ្តាប្រទេសដទៃនោះផងដែរ។

*សម្ផស្ស*

# កម្ពុជានៅលើផ្លូវឆ្ពោះទៅរៀបចំព្រះរាជពិធីបុណ្យអុំទូក អកអំបុក និងសំពះព្រះខែជាថ្មី

ព្រះរាជពិធីបុណ្យអុំទូក អកអំបុក និងសំពះព្រះខែ ជាពិធីបុណ្យប្រពៃណីដែលប្រជាពលរដ្ឋ តែងតែបានរីករាយ នៅរៀលរាល់ឆ្នាំក្នុងអំឡុងខែវិច្ឆិកា បានខក-ខាននៅក្នុងរយៈពេល ប៉ុន្មានឆ្នាំមុននេះ នឹងវិលមកវិញនៅក្នុងឆ្នាំនេះ ពោលគឺនៅថ្ងៃទី១៣-១៥ ខែវិច្ឆិកា ឆ្នាំ២០១៦។

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសរួចហើយពីការប្តេជ្ញាចិត្ត នៅក្នុងការរៀបចំព្រះរាជពិធីបុណ្យនេះជាថ្មីកាលពីពេលថ្មីៗកន្លងទៅ បន្ទាប់ពីរអាក់រអួលជាបន្តបន្ទាប់ ចាប់តាំងពី ឆ្នាំ២០១១ មក។

ជាក់ស្តែងកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ នៅទីក្រុងតាខ្មៅ សម្តេចតេជោ ហ៊ុន សែន បានអញ្ជើញធ្វើជាអធិបតីភាពពិធីបុណ្យអុំទូក ចំនួន៣២ គូ ដែលមកពីខេត្តកណ្តាល ដើម្បីជ្រើសរើសទូកដែលល្អសម្រាប់មកចូលរួមប្រកួតនៅក្នុងទីក្រុងភ្នំពេញ ដើម្បីផ្សព្វផ្សាយទេសចរណ៍ប្រពៃណី និងទំនៀមទម្លាប់ និងរំឭកអំពីភាពក្លាហាននៃកងទ័ពជើងទឹកកម្ពុជាកាលពីសម័យបុរាណ ។

ចាប់តាំងពីឆ្នាំ២០១១ មក ព្រះរាជពិធីបុណ្យនេះបានរអាក់រអួលជាបន្តបន្ទាប់ដោយ ពីឆ្នាំ២០១១ ខកខានដោយសារតែបញ្ហាទឹកជំនន់ខ្លាំង ក្រោយមកនៅក្នុង ២០១២ ខកខានទៀត ដោយសារតែ កាន់ទុក្ខសម្តេចព្រះនរោត្តម សីហនុ ដែលបានសោយទិវង្គត កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២។ នៅឆ្នាំ២០១៣ ក៏លុបចោលជាថ្មីទៀត ដោយសារតែទឹកជំនន់ជាថ្មី។ នាឆ្នាំ២០១៤ កម្ពុជាបានរៀបចំពិធីបុណ្យនេះជាថ្មី ក្រោមអធិបតីភាពរបស់ព្រះករុណា នរោត្តម សីហមុនី ព្រះមហាក្សត្រនៃរាជាណាចក្រកម្ពុជា ដោយមានការចូលរួមដោយទូកប្រមាណជា ២៤៨ ទូក និងមានអ្នកចែវ និងអ្នកអុំសរុបចំនួន ១៧.៤២០ នាក់។

នៅក្នុងឆ្នាំ ២០១៥ ព្រះរាជពិធីបុណ្យនេះ បានត្រូវខកខានជាថ្មី ដោយសារតែបញ្ហានៃគ្រោះរាំងស្ងួត ខណៈដែល អ្នកវិភាគមួយចំនួន បានអះអាងថា គឺដោយសារតែ ក្តីបារម្ភអំពីបញ្ហាសន្តិសុខសុវត្ថិភាព ដោយសារតែការបោះឆ្នោតបញ្ចប់តំណែងលោក កឹម សុខា ប្រធានស្តីទីគណបក្សសង្គ្រោះជាតិ ចេញពីតំណែងអនុប្រធានសភាទី១។ នាឆ្នាំនោះ ខុសពីឆ្នាំ ២០១១ដល់២០១៣ ដោយសារតែបើទោះបីជាមិនមានពិធីអុំទូក ប៉ុន្តែមានពិធីកំសាន្តការប្រគុំតន្ត្រី និងមានប្រជាពលរដ្ឋជាច្រើនម៉ឺននាក់ បានមករីករាយពិធីបុណ្យនេះនៅរាជធានីភ្នំពេញ ។

គួរឲ្យកត់សំគាល់ថា ទោះបីជាព្រះរាជពិធីនេះមិនបានរៀបចំ នៅក្នុងអំឡុងពីឆ្នាំ២០១១-២០១៣ និង២០១៥ ក៏ពិតមែន ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជានៅតែអនុញ្ញាតឲ្យថ្ងៃនោះ ជាថ្ងៃសម្រាក ហើយព្រះរាជពិធីអកអំបុក និងសំពះព្រះខែ ក៏ដូចជា អុំទូក គឺនៅតែរៀបចំនៅតាមមូល-ដ្ឋានបានដដែល គ្រាន់តែមិនបានមកជួបជុំគ្នារីករាយនៅរាជធានីភ្នំពេញ។

លោក ហេង សុខពិទូរ ជាប្រជាពលរដ្ឋមួយរូបដែលរស់នៅក្នុងទីក្រុងភ្នំពេញបានឲ្យដឹងថា កម្ពុជាមានបុណ្យប្រពៃណីច្រើន និងឈប់សម្រាកក៏ច្រើនដែរ ប៉ុន្តែបុណ្យអុំទូក អកអំបុក សំពះព្រះខែនេះ ហាក់ខុសគេបន្តិច ។

លោកបានបញ្ជាក់ថា សម្រាប់ពិធីបុណ្យផ្សេងៗ ជាពិសេសឲ្យតែថ្ងៃសម្រាកប្រជា-ពលរដ្ឋនៅក្នុងទីក្រុងភ្នំពេញ គឺតែងតនិយមចាកចេញពីរាជធានីទៅកាន់ រមណី-ដ្ឋានកំសាន្តផ្សេងៗ ឡើងស្វាត់។ ប៉ុន្តែនៅរៀងរាល់ពេលរៀបចំព្រះរាជពិធីបុណ្យនេះប្រជាពលរដ្ឋកម្ពុជាតែងតែនិយមធ្វើដំណើរមកពីបណ្តាខេត្តផ្សេងៗមកជួបជុំគ្នា នៅរាជធានីភ្នំពេញវិញ ពោលគឺរាប់លាននាក់ ។

លោក ជិត សារិន ជាអ្នករត់ម៉ូតូកង់បីមួយរូប បានអះអាងថា ប្រសិនបើគ្មានការគ្រប់គ្រង នៅពេលពិធីបុណ្យនេះទេ ទីក្រុងភ្នំពេញគឺសុទ្ធតែមនុស្ស យានយន្ត ស្ទះគ្រប់ច្រកចេញចូលមករាជធានី និងតាមកន្លែងនៃការរៀបចំពិធីបុណ្យនេះ ពោលគឺនៅមាត់ទន្លេ ចាប់ពីផ្សាររាត្រីរហូតដល់កោះពេជ្រ វិមានឯករាជ្យ។

*ដោយ អរិយបុត្រ*

# វាចាពលរដ្ឋ៖ ទាល់តែប្រមុខរដ្ឋាភិបាលបញ្ជាទើបសមត្ថកិ

ខេត្តមួយចំនួន ដោយរួមទាំងតំបន់ជាយរាជធានីភ្នំពេញជាច្រើនកន្លែងបានជន់លិច ក្រោយពេលដែល ភ្លៀងបានបង្អុរមកជាប់ៗគ្នា នៅក្នុងរយៈពេលប៉ុន្មានសប្តាហ៍ចុងក្រោយនេះ ជាហេតុបណ្តាលឲ្យប្រជាពលរដ្ឋរងគ្រោះមួយចំនួន មានការខឹងសម្បារនឹងអាជ្ញាធរក្រោយពេលដែលបានជួប និងបានឃើញនូវទុក្ខលំបាកដោយសារតែគ្រោះធម្មជាតិនេះ។

លោក សាញ់ ចេតនា ដែលជាអ្នកដំណើរមួយរូបបានឆ្លងកាត់ស្ថានភាពទឹកជំនន់កំពុងតែជន់លិចនៅតំបន់ជើងឯកនៃរាជធានីភ្នំពេញបាននិយាយទាំងទឹកមុខមួរហ្មង កាលពីព្រឹកថ្ងៃទី២០ ខែតុលា ថា "ខ្ញុំជិះម៉ូតូតាមផ្លូវ ដែលទឹកកំពុងហូរកាត់យ៉ាងខ្លាំងឃើញកន្លែងខ្លះប្រជាពលរដ្ឋលោកជម្លៀសខ្លួនចេញមកពី ផ្ទះសម្បែងដែលលិច អត់ឃើញមានអាជ្ញាធរណាជួយសោះតែម្តង"។

លោកបានបញ្ជាក់ថា "ទឹកហូរខ្លាំងណាស់ បើកម៉ូតូមិនចង់កើត ហើយ កន្លែងខ្លះ ប្រជាពលរដ្ឋដើរហួតទឹកជិតត្រឹមកទៅហើយ រកមើលតែទូក អាជ្ញាធរណាមួយមកជួយជម្លៀសប្រជាពលរដ្ឋក៏អត់ឃើញដែរ ឃើញតែមន្ត្រីលុយទឹក ដើរចង្អុលត្រេចុះត្រេឡើង ឆ្កាដៃឆ្កាជើងប៉ុណ្ណោះ"។

លោកស្រី ខួច សម្ផស្ស ដែលបានដើរឆ្លងកាត់ចំណុចដែលទឹកជំនន់កំពុងហូរកាត់ខ្លាំងនៅលើកំណាត់ ផ្លូវលេខ២១៧ បានប្រាប់ឲ្យដឹងថា ទឹកលិចគ្មានសល់ទេ តំបន់ចាប់ពីស្ពានព្រែកជ្រៃមកដល់តំបន់ជើងឯង។ លោកស្រីបានបញ្ជាក់ថា "មើលពីលើផ្លូវទៅ ខ្ញុំឡើងខ្លាច ដោយសារតែខាងលិចផ្លូវ ឃើញសុទ្ធតែទឹក។ អ្នកដែលដើរនៅខាងលិចផ្លូវ ដូចជាមិនឃើញទឹកត្រឹមជង្គង់ទេ មានតែចង្កេះ កន្លែងខ្លះដល់ក្លៀកឯណោះ"។

ជុំវិញករណីទឹកលិច និងហូរកាត់ផ្លូវនៅក្នុងតំបន់នោះ ក្រសួងធនធានទឹក និងឧត្តុនិយម បានឲ្យដឹងថា នេះគឺជាគ្រោះធម្មជាតិ។ ក្រសួងបានប្រកាសថា ដោយសារតែ ភ្លៀងធ្លាក់ជាប់ៗគ្នាជាបន្តបន្ទាប់ នៅក្នុងរយៈពេល ប្រមាណជា ២ សប្តាហ៍ បានធ្វើឲ្យទំនប់សណ្តូរស្ទឹងព្រែកត្នោតបានដាច់ដោយជំនន់ទឹកភ្លៀង។

ប្រភពដដែលបានបន្តថា ទំហំដែលដាច់នោះ គឺមានប្រវែងប្រមាណ ៦០ ម ហើយមន្ត្រីជំនាញ បានត្រូវបញ្ជូនទៅជួសជុល ជាបន្ទាន់ ដោយមានការចូលរួមពីអាជ្ញាធរមានសមត្ថកិច្ចផងដែរ ។



ប្រភពដដែលបានបន្តថា រហូតដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ នេះ ជំនន់ស្ទឹងព្រែកត្នោតនៅតែមិនទាន់ស្រកចុះ ដោយសារមានភ្លៀងធ្លាក់បន្តបន្ទាប់។ ជារទឹកស្ទឹងព្រែកត្នោតកើនឡើងដល់ទៅប្រមាណ ១.២៥០ ម៉ែត្រគូប ក្នុង ១វិនាទី អាស្រ័យហេតុនេះ ក៏មានការបង្វែរទឹកជំនន់ តាមរយៈអាងទឹកតាសាល ទ្វារទឹករលាំងជ្រៃ ទ្វារទឹក ៧មករា នៅកំពង់ទួល និងប្រឡាយមេ ប្រឡាយរង មួយចំនួនទៀតដើម្បីឲ្យជារទឹកឲ្យហូរចេញពីទំនប់ ៧ មករា ចូលស្ទឹងព្រែកត្នោត ផ្នែកខាងក្រោម នៅត្រឹមកម្រិត ៧០០-៨០០ ម៉ែត្រគូបប៉ុណ្ណោះ ក្នុង១វិនាទី ដើម្បីជានាសុវត្ថិភាព ។

អាស្រ័យដោយសារតែជំនន់ទឹកភ្លៀងនេះ បានធ្វើឲ្យជន់លិចភូមិដ្ឋាន និង ផ្លូវគមនាគមន៍ មួយចំនួននៅក្នុងភូមិសាស្ត្រសង្កាត់ព្រៃសខណ្ឌដង្កោ និងភូមិទួលពង្រសង្កាត់ចោមចៅខណ្ឌពោធិ៍សែនជ័យមួយផ្នែកដែលនាំឲ្យប្រជាពលរដ្ឋមានការខឹងសម្បារ ។

ប្រជាពលរដ្ឋកម្ពុជាដែលបានឃើញនូវគ្រោះអាសន្នដោយទឹកជំនន់នៅជាយរាជធានីភ្នំពេញកាលពីពេលថ្មីៗនេះបានបង្ហាញចម្ងល់ជុំវិញសកម្មភាពរបស់មន្ត្រីអាជ្ញាធរមានសមត្ថកិច្ច។

លោក សម ប្រាថ្នា ដែលប្រាប់អត្តសញ្ញាណត្រឹមតែថា ជាប្រជាពលរដ្ឋមួយរូបដែលរស់នៅ ខេត្តបាត់ដំបង បាននិយាយនៅហាងកាហ្វេមួយ នៅម្តុំស្ថានីយរថយន្តក្រុងក្បែរទីស្តីការគណរដ្ឋមន្ត្រីថា បើតាមលោកយល់និងសង្កេត អាជ្ញាធរនិង សមត្ថកិច្ចនៅពេលបច្ចុប្បន្ននេះ ហាក់ដូចជាធ្វើ និងបំពេញការងារយកតែមុខម៉េចចឹងទេ។ លោកបានបន្តថា មកដល់ពេលនេះគឺវាដូចជាគ្រប់តែរឿង គ្រប់តែបញ្ហាទាល់តែមានការស្រែក ពីថ្នាក់កំពូលបានធ្វើហើយ ធ្វើតែមួយពេល ក៏ស្ងាត់បាត់ទៅវិញ ឈឹងតែម្តង តែដល់ពេលស្រែកក៏តាំង មួយប្រាវទៀត ហើយក៏ឈឹងទៅវិញទៀតទៅ។

លោកបានបន្តទៀតថា ដូចជារឿងបញ្ហាអន្តិសុខ គ្រោះរាំងស្ងួត រឿងតម្លៃស្រូវ រឿងទឹកជំនន់ថ្មីៗនេះ គឺបានតែមួយប្រាវហ្នឹង ហើយក៏ស្ងាត់ទៀតហើយ ។ លោកបានបន្តទៀតថា ជាក់ស្តែងដូចជារឿង ចោរកម្មជាដើម ពីក្រោយពេលដែលប្រមុខរដ្ឋាភិបាលមានប្រតិកម្មក៏តាំងនាំគ្នា ខ្នះខ្នែងចេញធ្វើ សកម្មភាពភ្លាមៗ តែដល់ឥឡូវនេះ រាងដូចជាមិនសូវសកម្មសោះ ហើយរឿងតម្លៃស្រូវ រឿងគ្រោះរាំងស្ងួត និងថ្មីៗនេះរឿងទឹកជំនន់ ក៏ប្រហែលជាដូចគ្នាដែរ។ លោកបានបន្តថាបើមាននៅឆ្នាំក្រោយទៀតប្រហែលជាទាល់តែ ប្រមុខរដ្ឋាភិបាលលោកចេញបទបញ្ជាតាមមីក្រូទៀត បានធ្វើ និងមានដំណោះស្រាយទៀត មិនខាន។

លោកបានបន្តទៀតថា " ខ្ញុំមិនយល់ហេតុអ្វីបានជាអាជ្ញាធរមានសមត្ថកិច្ចមិនត្រៀមយន្តការទុកជាមុន? ហេតុអ្វីក៏មិនធ្វើការ និងបំពេញការងារក៏ដូចជាដោះស្រាយបញ្ហាតាមថានានុក្រម?"។

លោកហេតុហ៊ិនជាអ្នករត់ម៉ូតូឌុបមានទីលំនៅនៅសង្កាត់រលួសខណ្ឌដង្កោ ដែលគេដឹងថា គឺជាសង្កាត់មមួយដែលរងគ្រោះដោយទឹកជំនន់ទឹកភ្លៀងបាននិយាយថាអាជ្ញាធរគេចុះមកតាស់ តាំងពីមុនពេលទឹកជំនន់ និងក្រោយពេលទឹកជំនន់។ លោកបានបន្តថា ខាងខណ្ឌគេចុះមកអប់រំចុះចែកជូនព័ត៌មានដែរហើយពេលទឹកលិចគេចុះមកចែកអំណោយអីដែរតែគ្មាន

# សកម្មឬ ?



*ថតដោយសាហការី ស៊ីអេសស៊ី*

នរណាចង់បានអំណោយទេគឺចង់តែទឹកកុំឲ្យលិចតែបើលិចគឺស្រកឲ្យលឿនតែនេះនៅហ្នឹងមិនដឹងយ៉ាងម៉េច?

លោកសនជ័យ នាយកប្រតិបត្តិអង្គការសម្ព័ន្ធគណនេយ្យភាពសង្គមបានថ្លែងថា ជុំវិញបញ្ហាគ្រោះធម្មជាតិ យើងចង់ឲ្យកម្ពុជាដកបទពិសោធន៍បន្ថែមទៀតជាមួយនឹង ប្រទេសជិតខាង ហើយត្រូវរួបរួមគ្នា។

លោកបានបន្តថា ដូចជានៅស្រុកថៃពេលមានគ្រោះធម្មជាតិ គឺគណបក្សនយោបាយ គឺបំភ្លេចភាព ជាសត្រូវនយោបាយរបស់គេចេញ ហើយរួបរួមគ្នាដោះស្រាយបញ្ហាសិន ប៉ុន្តែនៅកម្ពុជា គឺគណបក្សនយោបាយចេះតែកេងចំណេញពីគ្នាទៅវិញទៅមក។

ដោយឡែកជុំវិញអន្តរាគមរបស់អាជ្ញាធរមានការយឺតយ៉ាវនៅក្នុងការឆ្លើយតបនឹងបញ្ហា លោកសនជ័យបានដាក់ការសង្ស័យថា អាចថា រដ្ឋាភិបាលរៀបចំថវិការបង្ការគ្រោះមហន្តរាយនេះមានចំនួនតិច ហើយបើតាមលោកយល់ គឺថាអាជ្ញាធរមូលដ្ឋាន ដូចជា ឃុំ សង្កាត់ ស្រុក អីហ្នឹង ក៏ដូចជា អ្នកដែល ពាក់ព័ន្ធ គេកំពុងតែរង់ចាំមើលអាជ្ញាធរគ្រោះមហន្តរាយ។ គេអាចគិតថា នេះគឺមិនមែនជាការងាររបស់គេទេ ជាការងាររបស់គណកម្មការជាតិគ្រោះមហន្តរាយ ឥចឹងហើយ បានហាក់បីដូចជាមានការបញ្ជាំគ្នា។ ដូច្នេះ ប្រសិនបើយើងរៀបចំជាយុទ្ធសាស្រ្តថ្មីៗអី គឺលោកចង់ឲ្យ កម្មវិធីបង្ការ និងដោះស្រាយ គ្រោះមហន្តរាយនេះ ត្រូវបានដាក់បញ្ចូលទៅក្នុង កម្មវិធីអភិវឌ្ឍន៍នៅមូលដ្ឋាន។ ដូចជា ឲ្យឃុំសង្កាត់នីមួយៗ ត្រូវតែមានថវិការនៅក្នុងការដោះស្រាយបញ្ហាគ្រោះមហន្តរាយនេះតែម្តង ពោលគឺធ្វើយ៉ាងណាកុំឲ្យមានការរង់ចាំ។

លោកបានបញ្ជាក់ថា "តាមការសង្កេតរបស់ខ្ញុំ ប្រព័ន្ធការងាររបស់គណកម្មការជាតិគ្រោះមហន្តរាយនេះ គឺដូចជាមិនមានប្រព័ន្ធការងារនៅគៀកនឹងប្រជាពលរដ្ឋទេ ដូច្នេះ គួរតែមានមន្ត្រីនៅថ្នាក់ឃុំដែរ។ វាមិនត្រូវទុកដល់ពេលដែលមានមនុស្សស្លាប់ហើយ បានចាត់វិធានការណ៍ គឺវាមិនត្រូវទេ។ គឺត្រូវតែមានវិធានការមុនសិន។ កំណែទម្រង់ស្អី បើមនុស្សនេះស្លាប់បាត់ទៅហើយនោះ។ ដូច្នេះ ត្រូវតែរកវិធានការសិន។

*ដោយ អរិយបុត្រ*

## យោបល់ពលរដ្ឋអំពីសកម្មភាពអាជ្ញាធនៅក្នុងការឆ្លើយតបនឹងបញ្ហា

ប្រជាពលរដ្ឋអរគុណចំពោះសកម្មភាពរបស់អាជ្ញាធរមូលដ្ឋានដែលបានខ្នះខ្នែងនៅក្នុងអំឡុងពេលមានបញ្ហាប៉ុន្តែជំរុញឲ្យមានដំណោះស្រាយច្បាស់លាស់ជាងនេះបន្ថែមទៀត។

លោកហេតុហ៊ិន ប្រជាពលរដ្ឋនៅសង្កាត់រលួស ខណ្ឌដង្កោ បានឲ្យដឹងថាលោកអរគុណចំពោះអំណោយជាអង្ករជាមីនិងព័ត៌មានផ្សេងៗដែលអាជ្ញាធរបានជួយ ប៉ុន្តែបើឆ្នាំក្រោយៗ អាជ្ញាធរអាចដោះស្រាយអារឿងលិចលង់នេះបានវាប្រសើរជាងអំណោយ។

លោកបញ្ជាក់ថា "អរគុណហើយលោកខាងខណ្ឌប៉ុន្តែបើឆ្នាំក្រោយៗអាចជួយរិះគិតយ៉ាងម៉េចកុំឲ្យលេចទៀតរិតតែអរគុណ"។

លោក កេតឫទ្ធាជាប្រជាពលរដ្ឋមួយរូបនៅខណ្ឌពោសែនជ័យបានឲ្យដឹងថាស្តាលូស្តាប្រឡាយគេត្រូវធ្វើត្រូវដោះសាឈ្រមុនពេលទឹកលិចមិនមែនទឹកលិចហើយបាននាំគ្នាទៅកាយប្រឡាយរើសសម្រាមនៅមាត់លូនោះទេ ។

លោកបានបញ្ជាក់ថា "ម៉ាប្រាំងដូចជាមិនឃើញនរណារវល់អីសោះដល់តែទឹកលិចដល់ច្រមុះប្រជាពលរដ្ឋបានមកស្ទុះស្ទារ"។

លោកបានបន្តថា "ពលរដ្ឋយើងអរគុណហើយដែលអាជ្ញាធរបានជួយប៉ុន្តែបើបានសកម្មមុននេះហើយទឹកអត់លិចយើងរិតតែអរគុណថែមទៀត"។

## ចំណាប់អារម្មណ៍របស់អ្នកវិភាគសង្គមជុំវិញសកម្មភាពរបស់អាជ្ញាធរក្នុងការឆ្លើយតបនឹងបញ្ហា

លោកហង្សវិទូជាប្រធានក្រុមអ្នកវិភាគវ័យក្មេងបានថ្លែងថាកន្លងមករហូតដល់នឹងបញ្ហាទឹកជំនន់ ថ្មីៗនេះការឆ្លើយតបនឹងបញ្ហានិងវិធានការក៏ដូចជាសកម្មភាពរបស់អាជ្ញាធរគឺហាក់ដូចជាខ្វះចន្លោះច្រើន ។

លោកបានបញ្ជាក់ថា "ប្រទេសកម្ពុជាតូចទេតែប្រៀបធៀបនឹងប្រទេសធំគឺមានមន្ត្រីមានអាជ្ញាធរច្រោងច្រាងច្រើនវាគួរតែអាចដោះស្រាយបញ្ហាបានច្រើននិងទាន់ពេលវេលាប៉ុន្តែនេះ"។

លោកបានបន្តថា ជុំវិញបញ្ហាចំណុចខ្វះខាត់របស់អាជ្ញាធរលើការដោះស្រាយបញ្ហាប្រជាពលរដ្ឋឲ្យទាន់ពេលវេលា ឬអនុវត្តតាមសារាចរណ៍ ឬបទបញ្ជានោះវាគ្មានប្រសិទ្ធិភាពនោះគឺដោយសារតែចំណុចបីសំខាន់។ ទីមួយសកម្មភាពភាគច្រើនគឺមិនសូវមានការគ្រោងទុក ការគិតទុកជាមុន។ ទីពីរគឺខ្វះកាតអនុវត្តនូវបទបញ្ជា និងសារាចរណ៍ណែនាំនោះឲ្យបានតឹងរ៉ឹងមានតម្លាភាពទី៣ គឺខ្វះការតាមដាន ។

លោកបានបន្តថា កន្លងមកអ្វីដែលរាជរដ្ឋាភិបាលបានដាក់ចេញនោះ គឺគ្មានការត្រួតពិនិត្យ ឡើងវិញទេ។

លោកបញ្ជាក់ថា "បើតាមខ្ញុំសង្កេតគឺនៅកម្ពុជាយើងមានតែការគិត និងការដាក់បញ្ជាតែប៉ុណ្ណោះប៉ុន្តែអត់មានការតាមដាន និងត្រួតពិនិត្យនោះទេនោះហើយជាចំណុចចន្លោះដែលរងការរិះគន់"។

លោកបានបន្តទៀតថាមកដល់ពេលនេះមន្ត្រីនិងអាជ្ញាធរហាក់ដូចជាបាត់បង់ព្រលឹងនិងអត់មានបេះដូងស្រលាញ់ជាតិនិងប្រជាពលរដ្ឋនោះទេដូច្នេះហើយនេះក៏ជាបញ្ហា។

លោកបានបញ្ជាក់ថា "ទោះបីជាមានប្រាក់ខែតិចមេមិនយកចិត្តទុកដាក់ប៉ុន្តែបើយើងមានក្តីស្រលាញ់ មានបេះដូងចំពោះជាតិនិងប្រជាជននោះយើងក៏អាចនឹងដោះស្រាយការងារបានល្អដែរ"។

# មរណភាពរបស់ស្ថាបនិកនៃអង្គការភាពញញឹមនៃកុមារធ្វើឲ្យមនុស្សរាប់លាននាក់រំជួលចិត្តជាខ្លាំង


ថតដោយ សម្ទស្ស

លោកគ្រីស្សង់ ហ្គោកឺឡាំង ដេប៉ាលីយ៉ែរ (Christian GAUQUELIN des PALLIERES) ដែលត្រូវបានគេស្គាល់ថាជាស្ថាបនិកនៃអង្គការភាពញញឹមនៃកុមារ ដែលជាអង្គការមួយបានជួយកុមារកំព្រា និងគ្មានទីពឹងស្ទើររាប់ពាន់នាក់ឲ្យ រៀនសូត្រ និងមានការងារល្អធ្វើក្នុងសង្គមនោះ ពេលនេះលោកបានទទួលមរណភាព ហើយ កាលពីវេលាម៉ោង៦:៥៨នាទីយប់ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦។

លោកគ្រីស្សង់ ទទួលមរណភាពដោយសាររោគាពាធ ក្នុងវ័យ៨២ឆ្នាំ នៅកន្លែងដ៏ជាទីស្រលាញ់របស់លោកនោះ គឺអង្គការភាពញញឹមនៃកុមារ ស្ថិតក្នុងផ្ទះលេខ ៤០២ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

សពរបស់លោកត្រូវបានតម្កល់នៅអង្គការភាពញញឹមនៃកុមារសង្កាត់ស្ទឹងមានជ័យដើម្បីធ្វើបុណ្យតាមប្រពៃណីខ្មែរដោយក្នុងនោះគេសង្កេតឃើញថាពិធីបុណ្យបានធ្វើតាមរបៀបពុទ្ធសាសនាផងនិងតាមបែបសាសនាកាតូលិកផង។

ការបាត់បង់លោកគ្រីស្សង់ ហ្គោកឺឡាំង ដេប៉ាលីយ៉ែរបានធ្វើឲ្យមនុស្សរាប់លានអ្នកជាពិសេសសិស្សានុសិស្សនៃអង្គការ (PSE)រាប់ម៉ឺននាក់ សម្ដែងនូវក្ដីសោកស្ដាយជាទីបំផុត ព្រោះពួកគេបានចាត់ទុកស្ថាបនិករូបនេះ ជាវីរបុរសដ៏អស្ចារ្យចំពោះកុមារៗជាច្រើនដែលចេញពីគំនរសំរាមក្នុងប្រទេសកម្ពុជាឲ្យបានឃើញពន្លឺថ្មីក្នុងជីវិត។

អង្គការភាពញញឹមនៃកុមារ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៩៤ ។អង្គការមួយនេះបង្កើតឡើងដោយប្ដីប្រពន្ធជាជនជាតិបារាំង គឺលោកគ្រីស្សង់ ហ្គោកឺឡាំង ដេប៉ាលីយ៉ែរ និងលោកស្រី ម៉ារីហ្វ្រង់ ដេប៉ាលីយ៉ែរ (Marie France des PALLIERES) បង្កើតឡើងក្នុងគោលដៅជួយសង្គ្រោះកុមាររើសសំរាម កុមារក្រីក្រគ្មានទីពឹង គ្មានផ្ទះស្នាក់អាស្រ័យត្រឹមត្រូវ ឬបាត់បង់ឪពុកម្ដាយជាដើម។ អង្គការនេះបានយកពួកគេមកអប់រំ ណែនាំ រៀនសូត្រ តាមកម្រិតនៃសាលារដ្ឋ ឬចំណេះដឹងទូទៅនៃកម្រិតសិក្សា បង្ហាត់បង្រៀនទាំងចំណេះដឹង ចំណេះធ្វើ និងជំនាញផ្សេងៗ ដល់កុមារ និងជួយរកការងារឲ្យធ្វើពេលបញ្ចប់ការសិក្សា។ បន្ថែមពីនេះក៏មានផ្ដល់នូវទីកន្លែងស្នាក់នៅដល់កុមារៗដែលភាគច្រើនមកពីជនបទ និងមួយចំនួនជាក្មេងកំព្រាឪពុកម្ដាយ។ គូស្វាមីភរិយាមួយគូនេះ ដែលជាស្ថាបនិកបានប្រើប្រាស់ថវិកាផ្ទាល់ខ្លួនទិញដីដ៏ធំមួយទំហំជាង ១ហិកតា និងបានសាងសង់ជាអាគារសិក្សា បណ្ណាល័យ បន្ទប់អាហារ បន្ទប់ស្នាក់នៅ និងអាគាររដ្ឋបាលទូទៅជាច្រើនទៀត ដើម្បីផ្គត់ផ្គង់ដល់ការរៀនសូត្រ និងរស់នៅរបស់កុមារៗ ។

លោកគ្រីស្សង់ ហ្គោកឺឡាំង ដេប៉ាលីយ៉ែ និងលោកស្រី ម៉ារីហ្វ្រង់ ដេប៉ាលីយ៉ែរបានចូលមករស់នៅក្នុងទឹកដីនៃប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩០ហើយពួកគាត់បានស្នើទៅដល់ព្រះមហាក្សត្រដើម្បីសុំចូលជាសញ្ជាតិខ្មែរ ក៏ត្រូវបានព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ឡាយព្រះហស្ដឯកភាពតាំងពីឆ្នាំ២០០៤។

លោកគ្រីស្សង់ ហ្គោកឺឡាំង ដេប៉ាលីយ៉ែរ ប្រសូតនៅថ្ងៃទី២៧ កក្កដា ១៩៣៤ នៅក្បែរទីក្រុងប៉ារីស ប្រទេសបារាំង។ ក្នុងពេលជាយុវជន លោកបានចូលរៀនផ្នែកពាណិជ្ជកម្ម នៅរដ្ឋធានីប៉ារីស ហើយបន្ទាប់មក លោកបានចូលបម្រើកងទ័ព រយៈពេល៣ឆ្នាំ ក្នុងឋានៈជាមន្រ្តីយោធា។ លោកបានរៀបការនៅឆ្នាំ ១៩៦៤ និងមានបុត្រចំនួន៤នាក់។ នៅឆ្នាំ១៩៧៨ ប្ដីប្រពន្ធគ្រួសារដេប៉ាលីយ៉ែរ និងកូនទាំង៤នាក់ បានសម្រេចចិត្តធ្វើដំណើរផ្សងព្រេង រយៈពេល១ឆ្នាំកន្លះ តាមរយៈឡានបោះដំរំចល័តមួយគ្រឿង។ ពួកគេបានធ្វើដំណើរឆ្លងកាត់ប្រទេសជាច្រើន ដូចជា ក្រិច តួកគី អ៊ីរ៉ង់ ចិន ឥណ្ឌា អាហ្វហ្គានីស្ថាន និងបាគីស្ថានជាដើម។ ក្រោយពីដំណើរផ្សងព្រេងសុវង្វែងយល់ពីជីវិត និងពិភព-លោក ប្ដីប្រពន្ធ ដេប៉ាលីយ៉ែរ បាន សរសេរ សៀវភៅមួយ ចំណងជើងថា Quatre Enfants et un Rêve "កូនបួននាក់ និងក្ដីសុបិនមួយ"។

នៅឆ្នាំ១៩៩៣ លោកបានសម្រេចចិត្ត មកធ្វើការនៅស្រុកខ្មែរ ជាមួយនឹងអង្គការស៊ីប៉ា (Sipar) ដើម្បីជួយលើកស្ទួយវិស័យអប់រំ និងអំណាននៅកម្ពុជា។ ក្នុងអំឡុងពេលបម្រើការជាមួយអង្គការស៊ីប៉ា ពេលនោះហើយ ដែលគាត់បានឃើញពីទុក្ខលំបាកវេទនារបស់កុមារក្រីក្រតាមផ្លូវនៅភ្នំពេញ។ ថ្ងៃមួយ កុមារម្នាក់បាននិយាយប្រាប់គាត់អំពីស្ថានភាពនៅគំនរសំរាមស្ទឹងមានជ័យ។ ក្រោយពីបានមើលនៅទីនោះ គាត់តក់ស្លុត និងអាណិតអាសូរនៅពេលដែលបានឃើញកុមារជាច្រើនធ្វើការ និងរើសអេតចាយនៅលើគំនរសំរាម។

បន្ទាប់មកគាត់ក៏បានសម្រេចចិត្តលាឈប់ពីអង្គការ Sipar ហើយបែរមកបង្កើតអង្គការដើម្បីភាពញញឹមនៃកុមារ (PSE) នៅឆ្នាំ១៩៩៥។ មកទល់នឹងពេលនេះ PSE បានជួយកុមារកម្ពុជារាប់សិបពាន់នាក់ ឲ្យចាកចេញពីគំនរសំរាមស្ទឹងមានជ័យ និងឲ្យចាកចេញពីទុរគតភាព ហើយកុមារទាំងនោះទទួលបានការសិក្សា អាហារសម្លៀកបំពាក់ និងការស្នាក់នៅសមរម្យ ព្រមទាំងបណ្ដុះបណ្ដាលវិជ្ជាជីវៈថែមទៀតផង។ PSE មានបីខាសា គឺនៅភ្នំពេញ សៀមរាប និងក្រុងព្រះសីហនុ។

នៅថ្ងៃទី២៦ កញ្ញា ព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ បានយាងទៅគោរពវិញ្ញាណក្ខន្ធរបស់លោកគ្រីស្សង់ ហ្គោកឺឡាំង ដេប៉ាលីយ៉ែរផងដែរ។ សពរបស់លោកត្រូវបានបូជានៅវត្តឫស្សីសាញ់ នារាជធានីភ្នំពេញនៅរសៀលថ្ងៃចន្ទទី ២៦ កញ្ញា។ ធាតុរបស់លោកត្រូវបានបែងចែកជាបួនចំណែក ដោយ១ចំណែកត្រូវបញ្ជូនទៅប្រទេសបារាំង មួយចំណែកត្រូវដាក់តម្កល់នៅព្រះវិហារកាតូលិកព្រះកុមារយេស៊ូ(បឹងទំពុន) មួយចំណែកធំទៀតត្រូវបានបាចនៅលើអតីតទីលានគំនរសំរាម (ស្ទឹងមានជ័យ) នារាជធានីភ្នំពេញ និងនៅក្នុងទឹកទន្លេចតុមុខ។

*ដោយ ស្រីម៉ាច*


ថតដោយ សម្ទស្ស

# គ្រីស្តបរិស័ទជាកម្លាំងក្នុងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់



ថតដោយ សុធីរិទ្ធ

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានរៀបចំកម្មវិធីសន្និបាតគ្រីស្តបរិស័ទក្នុងភូមិភាគភ្នំពេញចាប់ពីថ្ងៃទី២២-២៤ ខែកញ្ញា ឆ្នាំ២០១៦ ក្រោមប្រធានបទ "សេចក្តីពិត សេរីភាព យុត្តិធម៌ ធម៌មេត្តាករុណា និងប្រណីសន្តោស" ក្រោមការដឹកនាំដោយលោកអភិបាលអូលីវីយេ ឆ្មិតហាស្លេជាអភិបាលប្រចាំព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងគ្រីស្តបរិស័ទចំនួន២៥០នាក់។

លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ថា ឆ្នាំនេះគឺជាឆ្នាំមហាករុណាទិគុណ ដែលយើងបានប្រមូលការអប់រំទាំងអស់ទាក់ទងនឹងសេចក្តីស្រលាញ់ ទាក់ទងនឹងធម៌មេត្តាករុណា ទាក់ទងនឹងការលើកលែងទោសដើម្បីយល់ថា យើងជាគ្រីស្តបរិស័ទរស់នៅក្នុងសង្គមបច្ចុប្បន្ននេះ ដើម្បីអនុវត្តនៅក្នុងសង្គមបច្ចុប្បន្ន។

លោកអភិបាលបានឲ្យដឹងថា កម្មវិធីសន្និបាត គឺឲ្យគ្រីស្តបរិស័ទគិតពិចារណា និងរកវិធីស្ថាបនាជាតិដោយចាប់ផ្តើមពីខ្លួនគេម្នាក់ៗ។ លោកអភិបាលបន្តថា "ដើម្បីបង្កើត ជាតិមួយត្រូវចេះស្រលាញ់គ្នាត្រូវចេះបង្កើតសន្តិភាពជាមួយគ្នា"។ លោកបន្ថែមថា គំរូនៃធម៌មេត្តាករុណាសម្រាប់អ្នកក្រីក្ររបស់អ្នកម្តាយតេរេសាដែលទើបប្រកាសជាសន្តីកាលថ្ងៃទី០៤ កញ្ញាកន្លងទៅ គឺជាកម្លាំងជំរុញមួយដ៏អស្ចារ្យសម្រាប់យើងជាព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា។ លោកភិបាលអូលីវីយេ ក៏សូមអញ្ជើញឲ្យគ្រីស្តបរិស័ទទាំងអស់ ទៅជាទូតនៃសុខសន្តិភាពសម្រាប់គ្នានិងគ្នា ស្របតាមព្រះទ័យស្រលាញ់របស់ព្រះជាម្ចាស់។

កញ្ញា ម៉ៅ ស្រីកែវ ជាគ្រីស្តបរិស័ទមួយរូបដែលកំពុងបម្រើការងារក្នុងការិយាល័យពលករបានឲ្យដឹងថា កម្មវិធីសន្និបាតគ្រីស្តបរិស័ទនេះពិតជាមានសារៈសំខាន់សម្រាប់យើងម្នាក់ៗដែលជាកម្លាំងរបស់ព្រះសហគមន៍កាតូលិកឲ្យយើងចូលជ្រៅនៅក្នុងឆ្នាំមហាករុណាទិគុណនេះ ដោយផ្តល់តម្លៃឲ្យអ្នកដទៃ ពន្យល់គេពីជីវិតនៃសេចក្តីស្រលាញ់ លើកទឹកចិត្តគេ បង្រៀនអំពីរបៀបនៃការរស់នៅប្រកបដោយសុខុមាលភាព មានយុត្តិធម៌ និងបង្ហាញឲ្យគេឃើញថា គេពិតជាមានសេរីភាពក្នុងជីវិត និងសេចក្តីស្រលាញ់ទៅកាន់មនុស្សនៅជុំវិញខ្លួន។

ក្នុងសន្និបាតនេះ គ្រីស្តបរិស័ទស្វែងយល់បន្ថែមអំពីការបម្រើក្នុងសង្គម និងរបៀបដែលពិភពលោកនាពេលបច្ចុប្បន្ននេះបានផ្លាស់ប្តូរ។ លោកអភិបាលបានពន្យល់ថា មនុស្សម្នាក់ៗមានសេចក្តីថ្លៃថ្នូរ ព្រោះព្រះជាម្ចាស់បានបង្កើតគេ និងគេជារូបតំណាងរបស់ព្រះអង្គ។ លោកអភិបាលបន្តថា ក្នុងនាមជាគ្រីស្តបរិស័ទគឺត្រូវគិតពីផលប្រយោជន៍រួម ដោយគោរពបុគ្គលម្នាក់ៗ ធ្វើយ៉ាងណាឲ្យមានសុខុមាលភាពក្នុងសង្គម និងត្រូវបង្កើតសុខសន្តិភាព។

លោកបានបន្ថែមថា មនុស្សទាំងអស់មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិទាំងអស់ក្នុងលោកដែលចាត់ទុកជាកម្មសិទ្ធិរួម ឧទាហរណ៍ដូចជាចំណីអាហារជាដើមដែលមនុស្សទូទៅត្រូវតែបានទទួល។ ដូច្នេះ គ្រីស្តបរិស័ទ អ្នកមានអំណាច អ្នកកាន់អំណាចត្រូវតែចែករំលែកទ្រព្យសម្បត្តិរបស់ខ្លួនជាពិសេសគឺអាហារ។ ជាមួយគ្នានេះដែរ លោកបានសង្កត់ធ្ងន់ថា សង្គមនីមួយៗត្រូវតែគាំទ្រគ្នាទៅវិញទៅមក ដោយអ្នកដែលស្ថិតក្នុងសង្គមកម្រិតខ្ពស់ត្រូវជួយដល់អ្នកក្នុងសង្គមកម្រិតទាប ដើម្បីទទួលបានផលប្រយោជន៍រួម។ មនុស្សទាំងអស់ត្រូវមានការទទួលខុសត្រូវ និងរួមចំណែកក្នុងកិច្ចការរួម ដោយមានសេរីភាពពិតប្រាកដ និងដោយយកចិត្តទុកដាក់អភិវឌ្ឍវប្បធម៌ ធនធានមនុស្សឲ្យមានលក្ខណៈរឹងប៉ឹង និងខ្លាំងក្លា។

លោកអភិបាបន្តថា សាមគ្គីភាពរបស់មនុស្សក៏សំខាន់ដែរ ព្រោះថាវាអាចកាត់បន្ថយភាពតានតឹងនិងងាយស្រួលដោះស្រាយទំនាស់នានា។ កត្តាសំខាន់នោះគឺឲ្យអ្នកក្រីក្ររួមសាមគ្គីគ្នា និងឲ្យអ្នកមាន និងអ្នកក្រួមគ្នា កម្មកររួមគ្នា ថៅកែនិងបុគ្គលិករួមគ្នា ដែលណែនាំឲ្យយើងមានរបៀបរៀបរយខាងសីលធម៌សង្គម និងសាមគ្គីភាពអន្តរជាតិទើបអាចធ្វើឲ្យពិភពលោកមានសន្តិភាពបាន។

លើសនេះទៀត លោកអភិបាលបានណែនាំនិងរំឭកដល់គ្រីស្តបរិស័ទឲ្យចូលរួមធ្វើសកម្មភាពមេត្តាករុណាលើវិស័យចំនួន៦គឺ ការសិក្សា សុខភាព ពលករ ការការពារធម្មជាតិ អន្តរសាសនា និងការណែនាំអ្នកក្រីក្រឲ្យចូលក្នុងសង្គម។

នេះជាសន្និបាតលើកទី៣ សម្រាប់គ្រីស្តបរិស័ទក្នុងឆ្នាំមេត្តាករុណាទិគុណបើគិតចាប់ពីឆ្នាំ២០១៤ មកដល់ពេលនេះ។

*ដោយ រឿន ស្រីម៉ាច*



ថតដោយ សុធីរិទ្ធ



ថតដោយ សុធីរិទ្ធ

# លោកបូជាចារ្យវ៉ាំងសង់ វិលត្រឡប់ទៅបារាំងវិញ



លោកបូជាចារ្យវ៉ាំងសង់ សេន័យឆាល់ បានធ្វើមាតុភូមិនិវត្ត ទៅកាន់ប្រទេសបារាំងវិញដើម្បីបន្តបេសកកម្មថ្មីមួយក្នុងក្រុមសាសនទូតទីក្រុងប៉ារីស (MEP) កាលពីថ្ងៃទី២៦ កញ្ញា ២០១៦។

ក្រោយពីកិច្ចប្រជុំក្រុមសាសនទូតទីក្រុងប៉ារីសទូទាំងពិភពលោកកាលពីខែកក្កដា នៅប្រទេសបារាំង លោកបូជាចារ្យវ៉ាំងសង់ត្រូវបានបោះឆ្នោតជ្រើសតាំងជាអនុប្រធានក្រុមសាសនទូតនៃទីក្រុងប៉ារីស។ ក្នុងអណត្តិនេះ លោកត្រូវបំពេញបេសកកម្មចំនួន៦ឆ្នាំនៅប្រទេសបារាំង។

បេសកកម្មរបស់លោកក្នុងរយៈពេល៦ឆ្នាំខាងមុខនេះ គឺមានតួនាទីផ្សព្វផ្សាយអំពីព្រះសហគមន៍នៅទ្វីបអាស៊ីឲ្យមនុស្សទាំងអស់ស្គាល់ ឲ្យគេស្រឡាញ់ ឲ្យគេអធិដ្ឋាន និងឲ្យគេឧបត្ថម្ភ។

លោកវ៉ាំងសង់ បានមានប្រសាសន៍ថា "ក្នុងរយៈពេលដែលខ្ញុំបានបម្រើព្រះសហគមន៍នេះ អ្វីដែលធ្វើឲ្យខ្ញុំរំភើបចិត្តច្រើនជាងគេ គឺខ្ញុំឃើញព្រះសហគមន៍កម្ពុជាកំពុងសាងសង់"។ លោកបានបន្តថា នេះជាព្រះសហគមន៍មួយដែលមានសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ពេញខ្លួនចំពោះអ្នកដទៃ ចំពោះអ្នកដែលអត់ទាន់ស្គាល់ព្រះយេស៊ូ។ លោកបានបន្ថែមថា "ខ្ញុំឃើញមានយុវជនច្រើន ព្រោះនៅកម្ពុជាមាន៥០ភាគរយមានអាយុតិចជាង២៥ឆ្នាំ។ នៅប្រទេសកម្ពុជាមានសេចក្ដីត្រូវការច្រើន តែព្រះសហគមន៍មានជំនឿមាំមួននិងសកម្មមែនទែន"។

លោកបូជាចារ្យវ៉ាំងសង់បន្ថែមទៀតថា លោកសូមអរគុណអស់បងប្អូនដែលបានទទួលស្វាគមន៍លោកដែលជាជនបរទេស ធ្វើឲ្យលោកមានអារម្មណ៍កក់ក្ដៅជាពិសេស គឺភាពញញឹមរបស់បងប្អូនទាំងពុទ្ធបរិស័ទ និងគ្រីស្តបរិស័ទ។

លោកបូជាចារ្យវ៉ាំងសង់ សេន័យឆាល់ បានមកដល់ប្រទេសកម្ពុជាក្នុងខែវិច្ឆិកា ឆ្នាំ២០០៧។ លោកបានបំពេញបេសកកម្មនៅតំបន់ខេត្តកំពង់ធំ ក្នុងភូមិភាគបាត់ដំបង។ ក្រោយមក គឺនៅព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញខាងជើង និងជាបូជាចារ្យទទួលខុសត្រូវនៅមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង ដែលមានព្រះវិហារព្រះកុមារយេស៊ូ (បឹងទំពុន) ព្រះវិហារព្រះបេះដូងព្រះយេស៊ូ (កោះនរា) និងព្រះវិហារសន្តីម៉ារី (តួតាំង)។

ក្នុងអំឡុងពេលប៉ុន្មានឆ្នាំនេះ លោកក៏មានតួនាទីជាទីប្រឹក្សាលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ ជាគ្រូបង្រៀននៅទេវវិទ្យាល័យ ជាគណៈកម្មការព្រះគម្ពីរតំណាងព្រះសហគមន៍កាតូលិក នៅក្នុងសមាគមគម្ពីរកម្ពុជា ជាអ្នកសម្របសម្រួលគណៈកម្មាការព្រះគម្ពីរ និងជាគ្រូបង្រៀននៅសាលាអប់រំគ្រីស្តបរិស័ទសន្តយ៉ូស្វីនផ្នែកព្រះគម្ពីរ។

# សិក្ខាសាលាតូរ្យតន្ត្រីនៅព្រែកប្បាស

សាលាបង្រៀនភ្លេងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបចំសិក្ខាសាលាតូរ្យតន្ត្រី សម្រាប់យុវជនយុវនារីក្នុងព្រះសហគមន៍តំបន់តាកែវ នៅព្រះសហគមន៍សន្តីតេរេសាព្រែកប្បាស ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ ដើម្បីពង្រឹងសមត្ថភាពក្រុមតន្ត្រីតាមព្រះសហគមន៍។

យុវជន ជ្រួយ សុផា ជាយុវជនមកពីព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀង បាន និយាយថា គាត់ពិតជាមានសេចក្ដីអរសប្បាយណាស់ដែលព្រះសហគមន៍បានបង្កើត សិក្ខាសាលាតូរ្យតន្ត្រីនេះ ត្បិតវាជាលើកទីមួយដែលគាត់បានចូលរួមប៉ុន្តែគាត់ទទួលបានមេរៀនជាច្រើនដូចជារបៀបអានអក្សរភ្លេង របៀបលេងភ្លេង និងអាចលេងភ្លេងបានបួនបទយ៉ាងស្ទាត់ជំនាញ។ សុផា បន្តថា សិក្ខាសាលានេះពិតជាមានសារៈសំខាន់ណាស់សម្រាប់គាត់ ព្រោះអាចឲ្យគាត់ចេះលេងភ្លេងដោយខ្លួនឯង ហើយក៏អាចជួយឲ្យគ្រីស្តបរិស័ទលើកតម្កើងព្រះជាម្ចាស់បានតាមរយៈតន្ត្រីផងដែរ។

លោក អ៊ុំ សាមាន ជាអ្នកសម្របសម្រួលសាលាបង្រៀនភ្លេងនៃភូមិភាគភ្នំពេញ មានប្រសាសន៍ថា សិក្ខាសាលានេះមានគោលបំណងជម្រុញឲ្យសិក្ខាកាមទាំងអស់ដែលមកពីបណ្ដាព្រះសហគមន៍ក្នុងមណ្ឌលសកម្មភាពតាកែវយល់ដឹង និងចេះប្រើប្រាស់ឧបករណ៍ភ្លេងសម្រាប់លេងនៅក្នុងអភិបូជា ឬក្នុងពិធីផ្សេងៗរបស់ព្រះសហគមន៍ដែលពួកគាត់រស់នៅ។ លោកបានបញ្ជាក់ថា នេះជាសិក្ខាសាលាលើកទី៤ហើយ ដែលសាលានេះបានបង្កើតឡើង។

លោកបូជាចារ្យ វង្សម៉ាសែន ហាតាផៃ (សាន់ដេ) ជាបូជាចារ្យតំណាងលោកអភិបាលក្នុងមណ្ឌលសិល្បៈ និងវប្បធម៌ភូមិភាគភ្នំពេញ នឹងជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍សន្តប៉ូល និងព្រះសហគមន៍សន្តីតេរេសាព្រែកប្បាស បានផ្ដល់ពាក្យផ្ដាំផ្ញើដល់សិក្ខាកាមថា អ្វីៗទាំងអស់ដែលលោកគ្រូបានបង្រៀនយើង ឲ្យយើងម្នាក់ៗខិតខំអនុវត្ត។ ប្រសិនបើយើងមានចំណេះដឹងហើយយើងមិនអនុវត្តនោះយើងលេងភ្លេងមិនបានទេ។ លោកបូជាចារ្យរូបនេះក៏បានបន្តថា សូមឲ្យសិក្ខាកាមម្នាក់យកចិត្តទុកដាក់ ជាពិសេសឲ្យមានទំនួលខុសត្រូវលើការងាររបស់ខ្លួនឲ្យបានល្អ។

នៅថ្ងៃបញ្ចប់នៃកម្មវិធីសិក្ខាសាលានេះ លោកអភិបាលអូលីវីយេ នៃភូមិភាគភ្នំពេញបានធ្វើជាអធិបតីក្នុងអភិបូជាដើម្បីបិទកម្មវិធី។ លោកអភិបាលអូលីវីយេ បានថ្លែងក្នុងធម្មទេសនាថា ក្រុមសិក្ខាកាមទាំងអស់ជាក្រុមតន្ត្រីដើម្បីកោតសរសើរព្រះជាម្ចាស់ ដោយសារនៅពេលយើងមានក្រុមភ្លេងនិងក្រុមចម្រៀងដែលលេងនិងច្រៀងបានពីរោះ នោះពិធីបុណ្យរបស់យើងឡើងដល់ព្រះជាម្ចាស់ហើយ។ លោកអភិបាលបានបន្តថា "ខ្ញុំសង្ឃឹមថា សិក្ខាសាលានេះអាចជួយឲ្យតាមព្រះសហគមន៍នីមួយៗនឹងមានក្រុមភ្លេង និងក្រុមចម្រៀងយ៉ាងច្បាស់លាស់ ដើម្បីជួយព្រះសហគមន៍យើងថ្វាយសក្ការបូជា និងការអធិដ្ឋានរបស់យើងកាន់តែអស្ចារ្យថែមទៀត។ ដូច្នេះសិក្ខាកាមទាំងអស់ត្រូវមានចិត្តតស៊ូ ដោយសារការរៀនភ្លេងមិនងាយស្រួលប៉ុន្មានទេ។

គួរបញ្ជាក់ផងដែរថា សិក្ខាកាមទាំង២៩នាក់មានមកពីព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀង ៥នាក់ (ស្រី១នាក់) ព្រះសហគមន៍សន្តីតេរេសាព្រែកប្បាស ១០នាក់ (ស្រី៤នាក់) សហគមបាទី ៩នាក់ (ស្រី៣នាក់) សហគមតាកែវ ២នាក់ (ស្រីទាំង២) សហគមន៍កំពង់អំពិល ៣នាក់ (ស្រីទាំង៣)។ បន្ទាប់ពីបញ្ចប់អភិបូជា លោកអភិបាលអូលីវីយេក៏បានចែក លិខិតបញ្ជាក់អំពីការចូលរួមឲ្យសិក្ខាកាមទាំងអស់។ *ដោយ សុធីរិទ្ធ*



*ថតដោយ សុធីរិទ្ធ*



# វ៉ាំងសង់ រ៉ូឡាំង (១៩៣២-១៩៧០)

## Vincent ROLLIN

## បូជាចារ្យសាសនទូតក្រៅប្រទេសនាក្រុងប៉ារីស

លោកវ៉ាំងសង់ រ៉ូឡាំង កើតនៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៣២ នៅម៉ង់តូប៉ង Montauban (តារនិងហ្គារ៉ូន - Tarn et Garonne)។ លោកចូលក្រុមសាសនទូតក្រៅប្រទេសក្រុងប៉ារីស។ លោកចូលសិក្សាទេវវិជ្ជានៅក្នុងមហាវិទ្យាល័យក្រេគ័រីយ៉ាំង (Grégorienne) ទីក្រុងរ៉ូម។ លោកទទួលការតែងតាំង ជាបូជាចារ្យនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៦២ ដើម្បីចាត់ឲ្យទៅប្រទេសកម្ពុជា។

លោកមកដល់ប្រទេសកម្ពុជា នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៦៣ ហើយរៀនភាសាខ្មែរនៅបាត់ដំបង និងភូមិកំពង់គោ។ នៅឆ្នាំ១៩៦៥ លោកទៅនៅខេត្តស្ទឹងត្រែង បន្ទាប់មកវិលត្រឡប់មកភ្នំពេញ ដើម្បីបង្រៀននៅអនុទេវវិទ្យាល័យ។ លោកចូលរួមក្រុម "ធម៌មេត្តារបស់ព្រះយេស៊ូ" ជាក្រុមចលនា ដែលអនុវត្តតាមគោលការណ៍ខាងផ្លូវវិញ្ញាណរបស់លោកបូជាចារ្យ នៅហ្វូកូល។

នៅឆ្នាំ ១៩៧០ រដ្ឋាភិបាលចាប់និងនិរទេសជនជាតិវៀតណាមនៅប្រទេសកម្ពុជា។ លោកបំពេញការងារជួយជនរងគ្រោះជាមួយគណៈកម្មការសង្គហៈរបស់ព្រះសហគមន៍កាតូលិក។ ជនរងគ្រោះប្រមាណ ១០០,០០០ នាក់ រស់នៅចង្អៀតចង្អល់ណែនណាន់តាន់តាប់នៅជំរំនានាដែលបើកដោយអាជ្ញាធរស៊ីវិល។ ជាពិសេសនៅក្នុងកន្លែងព្រះសហគមន៍កាតូលិក។

"ខ្ញុំតែងតែចង់ស្លាប់នៅពេលខ្ញុំនៅវ័យក្មេង" លោកសរសេរក្នុងសម្ពន្ធមេត្រីរបស់លោក។ "ប្រហែលវាជាអាត្មានិយម និងជាការគេចពីការទទួលខុសត្រូវ និងបញ្ហាប្រឈមមុខនៃជីវិត។ ប៉ុន្តែវាក៏ជាបំណងប្រាថ្នា ដែលខ្ញុំអាចរកការរស់នៅនៅជិតជាមួយព្រះជាម្ចាស់ដែលខ្ញុំចង់ឧទ្ទិសជីវិតរបស់ខ្ញុំឲ្យ"

លោករ៉ូឡាំង ជួយរក្សាការទំនាក់ទំនងជាមួយសហគមន៍គ្រីស្តបរិស័ទ ដែលត្រូវគំរាមកំហែងពីកងទ័ពកម្មុយនីស្តវៀតកុង និងខ្មែរក្រហម។

នៅថ្ងៃទី៥ ឧសភា ១៩៧០ លោកធ្វើដំណើរទៅសួរសុខទុក្ខគ្រីស្តបរិស័ទនៅតំបន់ សំរោងធំ ជាមួយលោកក្លូដែលជាមិត្តសម្លាញ់របស់លោក ដើម្បីជួយបំពេញសេចក្តីត្រូវ និងផ្តល់ជំនួយឲ្យប្រជាជន។ បន្ទាប់មកពួកលោកនាំគ្នាទៅអ្នកលឿង តាមបណ្តោយផ្លូវទៅសៃហ្គន។ ពួកទាហានកម្មុយនីស្តបានចាប់ លោកទាំងពីរ ពីទន្លេមេគង្គ នៅដីក្រហម ហើយសម្លាប់លោកនៅទីនោះ៕



សន្ត ហ្វ្រង់ស៊ីស្កូ សាវីយេ

លោក ហ្វ្រង់ស៊ីស្កូ សាវីយ កើតនៅឆ្នាំ១៥០៦ នៅប្រទេសអេស្ប៉ាញ ពីត្រកូលអភិជន។ គាត់ទៅរៀនសូត្រនៅមហាវិទ្យាល័យ នៅទីក្រុងប៉ារីស។ នៅទីនោះ គាត់ជួបនិស្សិតម្នាក់ ឈ្មោះ អ៊ីញ៉ាស។ ក្រោយមកពួកគាត់ និងបុរសប្អូននាក់ផ្សេងទៀត ថ្វាយខ្លួនទាំងស្រុង ចំពោះព្រះយេស៊ូ និងបង្កើតក្រុមគ្រួសារបព្វជិតមួយ ដែលមានឈ្មោះថា ៖ សហគមន៍សហជីវិនរបស់ព្រះយេស៊ូ។

លោក ហ្វ្រង់ស៊ីស្កូ សាវីយ ទទួលអគ្គសញ្ញាតែងតាំងធ្វើជាបូជាចារ្យ រួចចេញដំណើរទៅប្រកាសដំណឹងល្អនៅទ្វីបអាស៊ី។ ទោះបីមានឧបសគ្គជាច្រើនរាប់មិនអស់ក៏ដោយ ក៏គាត់ទៅប្រទេសឥណ្ឌា ម៉ាឡេស៊ី ឥណ្ឌូណេស៊ី និងជប៉ុន។ គាត់មាន ចិត្តខ្នះខ្នែងឲ្យមនុស្សទាំងឡាយស្គាល់ និងស្រឡាញ់ព្រះជាម្ចាស់ ទាំងស្របតាមចរិត និងវប្បធម៌របស់មនុស្សម្នាក់ៗ។ គាត់ធ្វើអគ្គសញ្ញាជ្រមុជទឹកដល់មនុស្សរាប់ពាន់នាក់។ គាត់មានប្រសាសន៍ថា៖ ធ្លាក់ឋាននរក ប្រសើរជាងមិនទៅប្រកាសដំណឹងល្អ។ លោក ហ្វ្រង់ស៊ីស្កូ សាវីយេ ទទួលមរណភាពនៅពេលគាត់មានបំណងចង់ទៅប្រកាសដំណឹងល្អនៅប្រទេសចិន។ ពេលនោះ គាត់អាយុ៤៦ឆ្នាំ។ សន្ត ហ្វ្រង់ស៊ីស្កូ សាវីយេ ជាគំរូឲ្យយើងមានភ្លើងនៃសេចក្តីស្រឡាញ់នៅក្នុងដួងចិត្តយើង ទាំងមានបំណងប្រាថ្នាយ៉ាងខ្លាំងបំផុត ទៅប្រកាសដំណឹងល្អដល់មនុស្សទូទាំងពិភពលោក។

## កំណាព្យ មុននឹងជឿពាក្យគេត្រូវពិចារណាសិន

(បទពាក្យ ៧)



និពន្ធដោយអ្នកស្រី ខុង ណារី,
មន្ត្រីគ្រប់គ្រងកម្មវិធីអប់រំ និង សុខភាព
នៃគម្រោងអភិវឌ្ឍន៍ជនបទ អង្គស្នួល/
JSC

១-រុក្ខជាតិមួយដើមមានផ្លែផ្កា ស្លឹកមែកសាខាម្លប់ត្រឈៃ
គ្រប់សត្វបក្សានិងបក្សី ម្រឹគី-គាក្តីជ្រកទីស្ថាន ។
២-ប្រៀបដូចជាផ្ទះយ៉ាងរឹងមាំ ហើយជាទ្រនំទំសុខសាន្ត
អស់សត្វតូចធំជុំសម្រាន្ត យប់ថ្ងៃតែងក្សាន្តឥតមានហ្មង។
៣- រដូវវស្សាក៏ដូចប្រាំង រុក្ខាឈរបាំងឃាំងគ្រប់គ្រង
ព្យុះភ្លៀងបោកបក់ខ្លាំងកន្លង មានថ្ងៃក្តៅផងពាំងការពារ ។
៤-ផ្លែទុំខ្ចីចាស់រាល់រដូវ ផ្អែមឆ្ងាញ់ពេកក្រៃគ្រប់វេលា
បក្សាបក្សីទាំងម្រឹគា ធីទាំងអស់គ្នាឥតកង្វល់ ។
៥-សត្វស្លាបតែងចឹកទម្លាក់ទៅ ចតុប្បាទនៅទទួលផល
ធីផ្លែផល្លាពុំមានខ្វល់ រួមរស់សុខសល់ជាបងប្អូន ។
៦-ថ្ងៃមួយប្រែក្លាយជាប្រេះឆា សាច់ញាតិស្នេហាធ្លាប់រលូន
បែកបាក់សាមគ្គីជិតស្និទ្ធសូន្យ កាត់ផ្តាច់ចោលក្បួនផ្លូវជីវិត។
៧-ជឿពាក្យញុះញង់សត្វដទៃ ដែលរស់ឆ្ងាយព្រៃមកប្រឌិត
ពពួកសត្វធំម្តេចមិនគិត ចាញ់សត្វតូចល្អិតគិតមើលស្រាល។
៨-ផ្លែឈើលើដើមវាធីស្រាប់ ស៊ីសល់ទើបចាប់ខ្ទាក់ត្រកាល
ជំរុះមកដីក្រហមប្រាល ពួកឯងត្រអាលស៊ីដែលវា ។
៩-ត្រូវតែរំលំកំចាត់ចោល បំបាត់ស្រមោលឫសកែវវា
កំទេចឲ្យអស់ឈប់ការពារ យើងអត់វេទនាមិនខ្វះព្រៃ ។
១០-ជាមិត្តសម្លាញ់រួមសុខសាន្ត ប្រែប្រាស់ចាកស្ថានគ្នាទីទៃ
អាក្រក់រុក្ខាគ្មានតម្លៃ ផ្តល់ម្លប់យប់ថ្ងៃបែរអាស្រូវ។
១១-ហេវហត់កម្លាំងទាំងកាយចិត្ត ប្រាសប្រាណដេកស្និទ្ធបិតក្រោមនៅ
ផ្លែទុំក្រហមពមធ្មិនធ្មៅ ធីអស់សំដៅរំលើងគល់ ។

# លោកបូជាចារ្យ និងឧបដ្ឋាក កាតូលិកជាតិកម្ពុជាជួបគ្នានៅភ្នំពេញថ្មី



ថតដោយ លី សុវណ្ណា

លោកបូជាចារ្យ និងឧបដ្ឋាកកាតូលិកជាតិកម្ពុជា ចំនួន៩ បានជួបជុំគ្នារយៈពេល ៣ថ្ងៃ ក្នុងពិធីសំណាក់ធម៌តាមបែបព្រះ-សហគមន៍កាតូលិក នៅព្រះវិហារសន្តសិលា និងសន្តប៉ូល ភ្នំពេញថ្មី។ បើតាមប្រសាសន៍លោកបូជាចារ្យ សិលា ទម្លាប់ សុផល ការជួបជុំគ្នានេះជាសញ្ញាល្អមួយសម្រាប់បូជាចារ្យជាតិកម្ពុជា ក្នុងការជួបគ្នា ចែកបទពិសោធន៍ជាមួយគ្នា ស្គាល់គ្នាកាន់តែស៊ីជម្រៅថែមទៀត លើកិច្ចបម្រើព្រះសហគមន៍កាតូលិកតាមកន្លែងនីមួយៗ។ លោកបន្តថា "នេះជាពេលវេលាផងដែរសម្រាប់បូជាចារ្យខ្មែរ រិះគិតថា តើត្រូវបម្រើ និងកសាងព្រះសហគមន៍កាតូលិកនៅកម្ពុជាយ៉ាងដូចម្តេច"។

អាចនិយាយបានថា នេះជាលើកទីមួយដែលលោកបូជាចារ្យ ខ្មែរទាំងអស់បានជុំគ្នាទាំង៩នាក់។ អស់បម្រើនៅភូមិភាគផ្សេងៗគ្នា គឺ៣នាក់នៅព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង មានដូចជា លោកបូជាចារ្យ សិលា ទម្លាប់ សុផល លោកបូជាចារ្យ ដូមីនីក ង៉ែត វិន័យ និង យ៉ូសែប មួង រស់។ នៅព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មាន៣នាក់ គឺ លោកបូជាចារ្យ យ៉ូហាន អ៊ុន សុន លោកបូជាចារ្យ សិលា សួន ហង្ស លី និងលោកបូជាចារ្យ សិលា សុខ ណា។ ចំណែក ៣ នាក់ទៀតបម្រើនៅព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម មានដូចជា លោកបូជាចារ្យ ឡាយ ប៉ូល លោកបូជាចារ្យ យ៉ូហានម៉ារីយ៉ាណែរ ផាន បូរី និងលោកឧបដ្ឋាក ស្តេផាន សែ សាត ដែលនឹងតែងតាំង ជាបូជាចារ្យនៅក្នុងខែវិច្ឆិកានេះ។

តាមការពិភាក្សា ក្រុមលោកបូជាចារ្យនឹងបន្តជួបគ្នា៤ដង ក្នុងមួយឆ្នាំ រួមទាំងសំណាក់ធម៌ប្រចាំឆ្នាំ។ សូមបញ្ជាក់ថា ការជួបជុំនេះ នឹងមិនរាប់បញ្ចូលការសំណាក់ធម៌ ប្រចាំឆ្នាំរបស់បូជាចារ្យទាំងបីភូមិភាគនៅប្រទេសកម្ពុជានោះទេ។ ព្រះសហគមន៍កាតូលិកនៅកម្ពុជាបានកើតឡើងតាំងពីឆ្នាំ១៥៥៥ ហើយបានឆ្លងកាត់រាល់ព្រឹត្តការណ៍ប្រវត្តិសាស្ត្រនានារបស់ប្រទេសកម្ពុជា ទាំងអំណរសប្បាយ និងទុក្ខលំបាក។ ក្នុងសម័យអាវខ្មៅប៉ុលពត ព្រះសហគមន៍កាតូលិកត្រូវបានបំផ្លាញទាំងស្រុង អាគារ និងធន់ធានមនុស្ស លោកអភិបាល លោកបូជាចារ្យ បព្វជិត បព្វជិតា និងគ្រីស្តបរិស័ទជាតិកម្ពុជាជាច្រើនត្រូវបានសម្លាប់ និងស្លាប់ដោយសារជំនឿ និងការអត់ឃ្លាន។

ព្រះសហគមន៍ដ៏តូចនេះ ទោះបីបាត់អស់សំណង់អាគារ តែជំនឿក្នុងចំណោមគ្រីស្តបរិស័ទកាតូលិកកម្ពុជានៅតែមាន។ គ្រីស្តបរិស័ទ គឺជាថ្មដែលមានជីវិតក្នុង ការកសាងព្រះសហគមន៍ឲ្យរឹងមាំ។ នៅដើមទសវត្ស ១៩៩០ ព្រះសហគមន៍កាតូលិកបានទទួល ការអនុញ្ញាត ពីរដ្ឋអំណាចឡើង វិញ ក្នុងការអនុវត្តន៍ជំនឿដោយចំហរ និងចេញមុខបាន។

ក្នុងរយៈពេលជាង២០ឆ្នាំនេះ ព្រះ-សហគមន៍កាតូលិក បានរីកចម្រើនជាលំដាប់ និងបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គមកម្ពុជា។ ចំពោះការត្រាស់ហៅជាបូជាចារ្យ ជាបព្វជិត បព្វជិតា ក៏មានយុវជនចូលរួមជានិច្ច ទោះបីជាមានចំនួនតិចនៅឡើយ។

គ្រីស្តបរិស័ទកាតូលិកនៅកម្ពុជាមានប្រមាណជាង ពីរម៉ឺននាក់ (២០០០០ នាក់) មានបូជាចារ្យ និងបព្វជិត ចំនួនប្រមាណចិតសិបនាក់ (៧០នាក់) ក្នុងនោះបូជាចារ្យ និងឧបដ្ឋាកជាតិកម្ពុជាមានចំនួន ៩ ក្រៅពីនោះ គឺជាសាសនទូតមកពីក្រៅប្រទេស។ ចំណែកបព្វជិតាចំនួនប្រមាណ ជា១០០នាក់ ជាតិកម្ពុជាមានចំនួនតិចតួចបំផុត។ យុវជនកំពុងរៀនអំពីជីវិតជាបូជាចារ្យ នៅទេវវិទ្យា-ល័យ កម្ពុជាមានចំនួនជិត១០នាក់។

*ដោយ លី សុវណ្ណា*

# គ្រីស្តបរិស័ទដែលទទួលអគ្គសញ្ញាលាបថ្ងាសត្រូវធ្វើជាគ្រូពេទ្យដូចព្រះយេស៊ូ

លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ទៅកាន់បេក្ខជនទទួលអគ្គ-សញ្ញាលាបថ្ងាសឲ្យចេះបើកចិត្តគំនិត និងធ្វើជាគ្រូពេទ្យដើម្បីសង្គ្រោះមនុស្ស។ លោកអភិបាលបានមានប្រសាសន៍នេះក្នុងនៅឱកាសធ្វើអគ្គសញ្ញាលាបថ្ងាសឲ្យបេក្ខជនចំនួន១៥នាក់ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៦ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល ភ្នំពេញថ្មី រាជធានីភ្នំពេញ។

ថ្ងៃនេះជាឱកាសមួយឲ្យបើកភ្នែកថ្មីដោយមានដួងចិត្តថ្មី ដើម្បីជីវិតថ្មីដោយសារថ្ងៃនេះយើងបានទទួលដង្ហើមរបស់ព្រះជាម្ចាស់ ដែលចូលពេញខ្លួនរបស់យើងដើម្បីឲ្យយើងទៅជាគ្រូពេទ្យដូចព្រះយេស៊ូនៅតាមកន្លែងដែលយើងរស់នៅ។ គ្រូពេទ្យដូចព្រះយេស៊ូមានន័យថាដើម្បីជួយបងប្អូនដែលគ្មានសេចក្តីសង្ឃឹមក្នុងជីវិតឲ្យទទួលសេចក្តីសង្ឃឹម ដោយផ្តល់សេចក្តីស្រឡាញ់ការលើកទឹកចិត្ត ការសង្គ្រោះជាពិសេសណែនាំឲ្យគេមានជីវិតថ្មីដូចយើងបានទទួលពីព្រះជាម្ចាស់ដែរ។

លោក សេក ប៊ុនណា ជាបេក្ខជនដែលទទួលអគ្គសញ្ញាលាបថ្ងាស និងជាសមា-ជិកនៃក្រុមពិធីបុណ្យរបស់ព្រះសហគមន៍សន្តប៉ូល និងសន្តសិលាភ្នំពេញថ្មីបានឲ្យដឹងថា សម្រាប់យើងជាគ្រីស្តបរិស័ទគួរតែទទួលអគ្គសញ្ញាលាបថ្ងាសទាំងអស់គ្នា ព្រោះថា ប្រៀបដូចជាយើងបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធមកក្នុងខ្លួនយើង ដើម្បីឲ្យយើងបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ លោកក៏បានសំណូមពរថា បេក្ខជនដែលបានទទួលអគ្គសញ្ញា



ថតដោយ សុធីរិទ្ធ

លាបថ្ងាសហើយគួតែចំណាយពេលរបស់ខ្លួនមួយចំនួន ដើម្បីជួយព្រះសហគមន៍តាមរយៈចូលរួមក្រុមគណៈកម្មការផ្សេងៗ។

*ដោយ សុធីរិទ្ធ*

# ព្រះសហគមន៍កាតូលិកផ្តល់សេចក្តីសង្ឃឹមនិងភាពកក់ក្តៅដល់ចាស់ជរា

ដោយសម្លឹងឃើញជារួមថាភាគច្រើនចាស់ជរាកំពុងប្រឈមនឹងភាពលំបាកដូចជា ភាពក្រីក្រ ភាពឯកា បញ្ហាផ្លូវចិត្ត និងមិនសូវទទួលបានការយកចិត្តទុកដាក់ពីមជ្ឈដ្ឋានខាងក្រៅ ព្រះសហគមន៍កាតូលិកកំពង់ចាមក្រុងរួមសហការជាមួយនឹងក្រុមសន្តរ៉ាំងសង់នៅប៉ូលតំបន់កំពង់ចាមបានរៀបចំកម្មវិធីអំណរសប្បាយ និងសេចក្តីសង្ឃឹមសម្រាប់មនុស្សចាស់ប្រមាណ១០០នាក់។

លោកផាន ប៉ូរ៉ា អ្នកផ្តល់ប្រឹក្សាថ្នាក់ជាតិនៃក្រុមសន្តវ៉ាំងសង់នៅប៉ូលបានឲ្យដឹងថា ជីវិតរបស់មនុស្សចាស់ជរានៅក្នុងពេលបច្ចុប្បន្ន ទទួលរងនូវការលំបាកជាច្រើន គឺមានទាំងជីវភាព និងសុខភាពផ្លូវកាយនិងផ្លូវចិត្ត។

លោកប៉ូរ៉ាបន្ថែមថា ប្រសិនបើយើងគ្រាន់តែនិយាយនិងស្តាប់អំពីចាស់ជរា ប្រហែលជាយើងមិនដឹងលម្អិតអំពីស្ថានភាពរបស់ពួកគាត់នោះទេ។ តែប្រសិនបើយើងចូលទៅមើលឲ្យច្បាស់អំពីស្ថានភាពនៃការរស់នៅរបស់ពួកគាត់នោះ យើងនឹងដឹងថាមានមនុស្សចាស់ជាច្រើនដែលកំពុងតែរងទុក្ខវេទនា។ លោកប៉ូរ៉ាបន្តថា "ដូចជាពួកគាត់ត្រូវខិតខំប្រឹងប្រែងធ្វើការងារមួយចំនួនដើម្បីដូរយកអាហារមកបរិភោគ ដូចជាធ្វើអម្រឹង ធ្វើកន្ទេលអំបោស និងធ្វើនំលក់ជាដើម"។

ទន្ទឹមនឹងភាពលំបាកទាំងនេះ លោកប៉ូរ៉ាឲ្យដឹងទៀតថា មនុស្សចាស់ទាំងនោះខ្លះដេកឈឺនៅកន្ទេលព្រោះគ្មានអ្នកមើលថែនិងអ្នកខ្លះរស់នៅក្នុងខ្ទមតូចមួយដែលទ្រុឌទ្រោមខ្លាំងដោយភាពអស់សង្ឃឹមក្នុងជីវិត។


ថតដោយ ផានប៉ូរ៉ា

កម្មវិធីសម្រាប់ចាស់ជរានេះ បានរៀបចំឡើងកាលពីថ្ងៃទី០៩ តុលា នៅព្រះសហគមន៍កាតូលិកកំពង់ចាមក្រុងក្នុងខេត្តកំពង់ចាម ដែលមានលោកអភិបាលអន់តូនីសាមី ស៊ូសៃរាជ្យ ជាអភិបាលប្រចាំភូមិភាគកំពង់ចាមជាអធិបតី រួមនិងក្រុមយុវជនជនយុវនារីជាច្រើននាក់។

កម្មវិធីសម្រាប់ចាស់ជរានេះរួមមានការទស្សនារឿងអប់រំខ្លីដែលនិយាយអំពីតម្លៃរបស់មនុស្សចាស់ ការអប់រំអំពីអនាម័យ ការចែកសក្ខីភាពអំពីមនុស្សចាស់មួយចំនួនដែលធ្លាប់បាក់ទឹកចិត្ត តួនាទីរបស់មនុស្សចាស់នៅក្នុងសង្គម និងការពន្យល់ណែនាំដោយផ្ទាល់របស់លោកអភិបាលអន់តូនីសាមី អំពីតម្លៃនៃជីវិត និងសេក្តីស្រលាញ់របស់ព្រះជាម្ចាស់។

កម្មវិធីសម្រាប់មនុស្សចាស់នេះ គឺតែងតែប្រារព្ធជារៀងរាល់ឆ្នាំ ដែលធ្វើឡើង១០ឆ្នាំមកហើយ។ លោកប៉ូរ៉ាបញ្ជាក់ថាកន្លងមកក្រុមសន្តវ៉ាំងសង់នៅប៉ូល កំពុងតែយកចិត្តទុកដាក់ទៅលើពួកគាត់ដូចជាជួយឲ្យគាត់មកស្នាក់នៅក្នុងមណ្ឌលចាស់ជរា ជួយផ្តល់ស្បៀងអាហារឲ្យគាត់ និងការចុះទៅជួសជុលផ្ទះតាមតែអាចធ្វើទៅបាន ទោះពួកគាត់ដោយមិនគិតអំពីសាសនា។

*ដោយៈ រឿន ស្រីម៉ាច*

# បុណ្យគោរពសន្តបុគ្គលទាំងឡាយនៅព្រះវិហារព្រះកុមារយេស៊ូ

ព្រះវិហារព្រះកុមារយេស៊ូ នៅបឹងទំពុននៃមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង បានប្រារព្ធពិធីបុណ្យគោរពដល់សន្តបុគ្គលទាំងឡាយតាមជំនឿព្រះសហគមន៍កាតូលិក កាលពីថ្ងៃទី១ តុលា ២០១៦ ដោយមានលោកដាមីញ៉ាំង ហ្វាន័រ ជាអធិបតី។

នៅក្នុងធម្មទេសនាលោកបូជាចារ្យដាមីញ៉ាំង បានមានប្រសាសន៍ជំរុញគ្រីស្តបរិស័ទឲ្យយកគំរូតាមសន្តបុគ្គលដោយពន្យល់ថា សន្តបុគ្គលគឺជារៀមច្បងនៃជំនឿរបស់គ្រីស្តបរិស័ទដែលហ៊ានដើរតាមព្រះយេស៊ូដោយស្រឡាញ់ព្រះយេស៊ូ និងស្រឡាញ់យើងទាំងអស់គ្នា ព្រមទាំងរង់ចាំយើងនៅស្ថានបរមសុខព្រោះពួកគាត់ស្គាល់យើង។


ថតដោយ ដាលីស

លោកបូជាចារ្យបន្ថែមថា សន្តបុគ្គលគឺជាអ្នកដែលស្គាល់អំពីជីវិត និងចិត្តរបស់យើង ដោយសារពួកគាត់ធ្លាប់មានបទពិសោធន៍អំពីអំណរសប្បាយ និងទុក្ខព្រួយរបស់មនុស្ស។

លោកដាមីញ៉ាំង បានលើកទឹកចិត្តគ្រីស្តបរិស័ទទាំងអស់ ដោយនិយាយថា សន្តបុគ្គលក៏ធ្លាប់ជាអ្នកបាបដូចយើងដែរ គឺមិនមែនជាមនុស្សល្អឥតខ្ចោះនោះទេ តែពួកគេបានស្រឡាញ់ព្រះយេស៊ូហួសនិងអស់ពីសមត្ថភាពរបស់គេ។ លោកបន្តថា នៅពេលនេះសន្តបុគ្គល គឺជាអ្នកដែលមានសុភមង្គលនៅស្ថានបរមសុខ ហើយសុភមង្គលទាំងនោះគឺបានមកពីព្រះយេស៊ូផ្ទាល់ ព្រោះព្រះយេស៊ូ គឺជាប្រភពនៃសុភមង្គល ទោះបីព្រះអង្គនៅលើឈើឆ្កាងក៏ទ្រង់មានសុភមង្គលដោយបានសង្គ្រោះមនុស្សលោក។

ក្នុងកម្មវិធីបុណ្យនេះ លោកបូជាចារ្យ និងគ្រីស្តបរិស័ទទាំងអស់បានលុតជង្គង់ និងសូត្រធម៌អង្វរសន្តបុគ្គល ដើម្បីឲ្យពួកគាត់ជួយអង្វរព្រះជាម្ចាស់សម្រាប់គ្រីស្តបរិស័ទ និងមនុស្សលោកទាំងអស់។

បុណ្យភ្ជុំជាមរតកដែលបុព្វបុរសខ្មែរបន្សល់ទុកមកឲ្យកូនចៅជំនាន់ក្រោយ ហេតុនេះទោះជាយើងកាន់ជំនឿសាសនាអ្វីក៏ដោយក៏យើងជាពលរដ្ឋលើទឹកដីដ៏រុងរឿងមួយនេះ ប្រារព្ធពិធីបុណ្យនេះដែរ។ យើងអធិដ្ឋានអង្វរព្រះជាម្ចាស់សម្រាប់អស់វិញ្ញាណក្ខន្ធមរណបុគ្គលទាំងឡាយឲ្យបានចូលរួមនៅស្ថានបរមសុខរួមជាមួយព្រះអង្គផង និងសូមឲ្យអ្នកទាំងអស់នោះអង្វរព្រះជាម្ចាស់សម្រាប់យើង ឲ្យយើងមានជំនឿរឹងមាំលើព្រះជាម្ចាស់។ គ្រីស្តបរិស័ទយើងមិនជឿថាមានប្រែតទេ។ តាមប្រពៃណីរបស់ព្រះសហគមន៍កាតូលិក គឺគេប្រារព្ធសម្រាប់សន្តបុគ្គលទាំងឡាយ និងមរណបុគ្គលទាំងឡាយនៅថ្ងៃទី១-២ ខែវិច្ឆិកា តែព្រះសហគមន៍កាតូលិកនៅកម្ពុជាបានស្នើសុំការអនុញ្ញាតពីសន្តអសនៈលើកមកប្រារព្ធនៅថ្ងៃបុណ្យភ្ជុំវិញ តាមវប្បធម៌របស់កម្ពុជា សំណើរនេះបានទទួលការអនុញ្ញាតពីសន្តអសនៈ ក្នុងទស្សវត្សឆ្នាំ១៩៧០។

*ដោយ ដាលីស*

## សម្តេចប៉ាប រីករាយនឹងរបាំជនពិការនៅក្នុងដំណើរបំពេញទស្សនកិច្ចនៅចយចៀ

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ត្រូវបានទីភ្នាក់ងារព័ត៌មានកាតូលិករាយការណ៍ថា មានភាពរីករាយ និងបង្ហាញនូវមោទនភាពចំពោះក្រុមសិល្បៈយុវជនពិការ ដែលបានសំដែងជាពិសេសស្វាគមន៍សម្តេចនៅក្នុងដំណើរមកកាន់ប្រទេសចយចៀ។

សម្តេចប៉ាបបានបង្ហាញនូវភាពរីករាយ និងបានចែករំលែកនូវការកោតសរសើរចំពោះ ក្រុមរបាំយុវជនពិការ ដែលបានខិតខំសម្តែងឡើងដើម្បីស្វាគមន៍រូបសម្តេច សូម្បីតែពួកគេត្រូវសម្តែងទាំងរទេះក៏ដោយចុះ ។

ប្រភពដដែលបានឲ្យដឹងថា កម្មវិធីសម្តែងនេះ គឺរៀបចំឡើងនៅខាងក្រៅនៃអគារមជ្ឈមណ្ឌល ជំនួយមួយនៅក្នុងទីក្រុង ត្ពីលីហ្ស៊ី ដោយមានមនុស្សចូលរួមប្រមាណជាជាង ៧០០នាក់ ដែលពួកគេជាអ្នកជំងឺ ជនពិការ អ្នកស្ម័គ្រចិត្ត និងកម្មករមកពីអង្គការមនុស្សធម៌ផ្សេងៗ។

សម្តេចប៉ាបបានថ្លែងទៅកាន់សិល្បករជនពិការទាំងអស់នោះថា សម្តេចពិតជារីករាយដែលមានឱកាសបានឃើញពីសកម្មភាពរបស់ពួកគេ ហើយក៏បានថ្លែងលើកទឹកចិត្តពួកគេថែមទៀតថា ព្រះជាម្ចាស់មិនដែលរើសអើងទេ ហើយមនុស្សពិការក៏មិនមានសេចក្តីសង្ឃឹមនោះដែរ។

សម្តេចប៉ាបបានថ្លែងថា ព្រះយេស៊ូមិនដែលបង្រៀនមនុស្សឲ្យអស់សង្ឃឹមនោះទេ ទោះស្ថិតនៅក្នុងស្ថានភាពណាក៏ដោយ ហើយបានថ្លែងលើកទឹកចិត្តពួកគេបន្ថែមទៀត ។

## សន្តិភាព គឺត្រូវកសាងចេញមកពីយុត្តិធម៌ និង ការគោរពគ្នាទៅវិញទៅមក

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងនៅក្នុងពេលបំពេញទស្សនកិច្ច នៅក្នុងប្រទេសចយចៀរ កាលពីថ្ងៃទី៣០ ខែកញ្ញា សប្តាហ៍មុននេះថា សន្តិភាពពិតប្រាកដគឺត្រូវកសាងចេញមក ពីយុត្តិធម៌សង្គម និង ការគោរពគ្នាទៅវិញទៅមក។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងបន្តទៀតថា សន្តិភាពនៅក្នុងលើពិភពលោកនៅពេលបច្ចុប្បន្ននេះគឺមានបញ្ហានៅផ្នែកជាច្រើននៃពិភពលោក ប៉ុន្តែគេអាចនឹងកសាងសន្តិភាពមួយដ៏ពិតប្រាកដដរាបណា មនុស្សទាំងអស់គ្នា ទទួលបាននូវយុត្តិធម៌ និងការគោរពនៅដែនអធិតេយ្យភាពនៃសិទ្ធិ របស់ប្រជាជាតិនីមួយៗ រហូតដល់មនុស្សម្នាក់ៗ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបន្តទៀតថា សន្តិភាពគឺស្ថិតនៅក្នុងចំណោមមនុស្ស និងរដ្ឋនានា នៅលើតំបន់ផ្សេងៗនៃពិភពលោក គឺជាលក្ខខណ្ឌដែលមិនអាចខ្វះបានសម្រាប់ការរីកចម្រើនដ៏យូរអង្វែង។

សម្តេចប៉ាបបានប្រកាសថា "សន្តិភាពតម្រូវឲ្យមានការបង្កើនការជឿជាក់លើគ្នាទៅវិញទៅមក និងការពិចារណាដែលពុំអាចដាក់មួយឡែកនូវការគោរពសិទ្ធិផ្តាច់មុខនៃគ្រប់ប្រទេសក្នុងក្របខ័ណ្ឌនៃច្បាប់អន្តរជាតិនោះឡើយ"។

សម្តេចប៉ាបបានថ្លែងកត់សម្គាល់ថា នៅក្នុងកន្លែងជាច្រើននៅលើពិភពលោក "ជាវិធីមួយនៃការគិតដែលលេចធ្លោក្នុងការរក្សាភាពខុសគ្នាស្របច្បាប់ដែលអាចរារាំងការមិនយល់ស្របគ្នា និងដែលអាចកើតឡើង នៅក្នុងបរិយាកាសនៃកិច្ចសន្ទនាស៊ីវិល័យមួយ។

សម្តេចប៉ាបបានថ្លែងទៀតថា ការជំរុញការពិភាក្សាដោយផ្អែកលើភាពសមហេតុផល និងការទទួលខុស គឺត្រូវការចាំបាច់ជាពិសេសនៅក្នុងបរិបទនៃអាកាសធាតុជាសកលនាពេលបច្ចុប្បន្ន ហើយនិងអំពើហិង្សាជ្រុលនិយម ។

## ស្ត្រីចំណាស់១០១ឆ្នាំជនជាតិប្រេស៊ីលក្លាយជាគ្រីស្តបរិស័ទដែលចាស់បំផុតដែលទទួលព្រះកាយ

ស្ត្រីជនជាតិប្រេស៊ីលមួយរូបដែលមានវ័យ រហូតដល់ទី១០១ ឆ្នាំ បានក្លាយជាគ្រីស្តបរិស័ទ ដែលទទួលអគ្គសញ្ញាជ្រមុជទឹកនិងព្រះកាយដ៏ចំណាស់បំផុតនៅលើពិភពលោកនេះ។

ទីភ្នាក់ងារព័ត៌មានកាតូលិក បានអះអាងកាលពីថ្ងៃទី០២ តុលា ២០១៦ ថា លោកយាយ ដូណា ប៉េនញ៉ា គឺបានក្លាយជាគ្រីស្តបរិស័ទ ដ៏ចំណាស់បំផុតនៅលើពិភពលោកនេះ តាំងពី ថ្ងៃទី២៨ កញ្ញា ២០១៦។

ប្រភពដដែលបានថ្លែងថា លោកយាយបានទទួលអគ្គសញ្ញាជ្រមុជទឹក នៅថ្ងៃនោះ នាទីក្រុង រីយ៉ូ ឌឺ ចេនណៃរ៉ូ នៅក្រោមការអបអរ និងស្វាគមន៍ពីបណ្តាគ្រីស្តបរិស័ទនានា ដែលបានចូលរួមដើម្បីជាសក្ខីភាព នៃការស្ម័គ្រចិត្តទទួលសេចក្តីស្រលាញ់ពីព្រះជាម្ចាស់ និងព្រះសហគមន៍កាតូលិកនៅកម្ពុជា។

លោកស្រី ចូហ្សាន រីបៃរ៉ូ ជាគ្រីស្តបរិស័ទមួយរូប ដែលបានចូលរួមពិធីនេះ បានអះអាងថា នេះគឺពិតជាស្ញប់ស្ញែងមែនចំពោះលោកយាយ ដែលបានខិតខំសិក្សា និងអភិវឌ្ឍន៍រហូតដល់ដំណាក់កាលគាត់មានអាយុ ១០១ឆ្នាំ។

លោកយាយ ត្រូវបានគេដឹងថា បានមកដល់មណ្ឌលថែទាំសុខភាពមួយកន្លែងដែលកំពុងតែ ដំណើការដោយសមាគមក្រុមបងស្រី រ៉ូសារី នៅមុនពេលដែលលោកយាយបានប្រទះនឹងឱកាសបែបនេះ។

ថ្វីត្បិតតែលោកយាយមានអាយុ ១០១ ឆ្នាំ ក៏ពិតមែន ប៉ុន្តែលោកយាយមិនឲ្យខ្លួនលោកយាយ ជរា ទៅតាមវ័យនោះទេ គឺលោកយាយនៅរឹងមាំ ។

## សម្តេចប៉ាបថ្វាយពិធីអភិបូជានៅប្រទេស អាហ្សែបៃហ្សង់ ដោយជំរុញឲ្យគ្រីស្តបរិស័ទពង្រឹង ជំនឿ និងសកម្មភាពមនុស្សធម៌

កាលពីថ្ងៃអាទិត្យដើមសប្តាហ៍នេះ នៅពេលដែលបានទៅដល់ទឹកដីនៃប្រទេសអាហ្សែបៃហ្សង់ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានចូលរួមពិធីថ្វាយអភិបូជា មួយដោយនៅក្នុងឱកាសនោះ បានលើកឡើងនូវធម្មជាតិនៃជីវិតជាគ្រីស្តបរិស័ទ។

នាឱកាសនោះសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា ជំនឿ និងការបម្រើ គឺជាចំណុចខ្លឹមរបស់ជីវិតជាគ្រីស្តបរិស័ទដែលត្រូវត្របាញ់បញ្ចូលគ្នា ដូចជាកម្រាលព្រំ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា ជំនឿ និងការបម្រើមិនអាចផ្តាច់ចេញពីគ្នាបានទេ ពោលគឺវាត្រូវត្របាញ់បញ្ចូលគ្នាដូចជា កម្រាលព្រំដែលជាប្រពៃណីតម្បាញរបស់ជនជាតិអាហ្សែបៃហ្សង់ដូច្នេះដែរ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងទៀតថា តម្បាញនៃជំនឿនិងការបម្រើឲ្យចូលគ្នា គឺជារឿង ដែលចាំបាច់ ហើយ ក៏ជាស្នូលនៃជំនឿមិនថា សហគមន៍ណាមួយនោះទេ ឲ្យតែស្ថិតនៅក្នុងគ្រីស្តសាសនា ប៉ុន្តែវាទាមទារនូវភាពអំណត់អត់ធ្មត់ និងខន្តីនៅក្នុងចិត្តឲ្យបានច្រើនប្រសិនបើយើងទាំងអស់គ្នា ចង់ឲ្យជំនឿនិងការបម្រើនេះអាចត្របាញ់បញ្ចូលគ្នាជាធ្លុងមួយនោះ ។

សម្រាប់ជីវិតជាគ្រីស្តបរិស័ទ គឺត្រូវការស្វែងយល់ និងអនុវត្តព្រមទាំងជំហរមួយច្បាស់លាស់។

## គោលនយោបាយគាំទ្រជីវិតបានរក្សាការពារអាយុជីវិត ប្រមាណជា២ លាននាក់

ទីភ្នាក់ងារព័ត៌មានកាតូលិក បានរាយការណ៍ថា គោលនយោបាយគាំទ្រជីវិត ដែលបាន ឈានដល់៤០ឆ្នាំកាលពីចុងខែកញ្ញា កន្លងផុតទៅ នេះបានជួយសង្គ្រោះជីវិតទារកនិងទារិកាប្រមាណជា ២លាននាក់។

របាយការណ៍នៃការស្រាវជ្រាវមួយ ដែលបានចេញផ្សាយកាលពីពេលថ្មីៗនេះ បានអះអាងថា គោលនយោបាយនេះ បានជួយទារកនិងទារិកា ទាំងនេះគេចផុតពីការរំលូត។

លោក ចាក់ ដូណូវ៉ាន់ ប្រធាននៃវិទ្យាស្ថាន ឆាលូត លូហ្ស៊រ បានអះអាងថា គោលនយោបាយនេះ វាពិតជាមានប្រយោជន៍ណាស់នៅក្នុងការការពារជីវិត និងសង្គ្រោះជីវិត របស់មនុស្សប្រមាណជា ២ លាននាក់ ។

លោកបានបន្តថា ដោយសារតែគោលនយោបាយនេះពលរដ្ឋអាមេរិក គឺមានការស្វែងយល់ខ្ពស់ ហើយទើបអាចឈានទៅការពារនិងសម្រេចចិត្តជួយសង្គ្រោះជីវិតទាំងនោះ ។

នយោបាយគាំពារជីវិតនេះ ត្រូវបានស្នើដោយ លោក ហេនរី ហាយ នៅក្នុងឆ្នាំ ១៩៧៦ ក្រោយពេលដែលតុលាការកំពូល បានសម្រេចថា ស្ត្រីមានសិទ្ធិស្របច្បាប់នៅក្នុងការរំលូតកូនចោល ប៉ុន្តែដោយសារតែ គោលនយោបាយនេះ គឺមានការរឹតបន្តឹងការរំលូតនេះ ដោយអនុញ្ញាតតែស្ត្រីនៅក្នុងករណីរំលោភ ជំងឺ ឬហេតុការណ៍ដែល គ្រោះថ្នាក់ដល់ស្ត្រីជាមាតា ។

លោកបានបន្តទៀតថា ប្រសិនបើមិនមានគោលនយោបាយនេះ ស្ត្រីអាមេរិកម្នាក់នៅក្នុងចំណោម៩ នាក់នឹងសម្រេចចិត្តរំលូតកូន។



*ឧបដ្ឋាក សែ សាត*

### ថ្ងៃអាទិត្យ ទី២៧ នៃរដូវធម្មតា ឆ្នាំ គ (លក ១៧,៥-១០)

*"សូមព្រះអង្គប្រទានជំនឿមកយើងខ្ញុំថែមទៀត"*។ ជំនឿ ដែល យើងទូលសុំពីព្រះអង្គមិនមែនជាជំនឿដែលធ្វើឲ្យយើងមានចំណេះដឹងផ្នែកលទ្ធិនោះទេ។ អ្វីដែលយើងត្រូវទូលសុំនោះគឺ ឲ្យយើងផ្ញើជីវិត និងទុកចិត្តទាំងស្រុងទៅលើព្រះជាម្ចាស់ដោយដឹងថា ព្រះអង្គគង់នៅជាមួយយើង និងតាមថែរក្សាយើងជានិច្ច ទោះបីយើងមានអារម្មណ៍ថាព្រះអង្គគង់នៅឆ្ងាយពីយើងក្តី។ ការផ្ញើជីវិតនេះគ្មានន័យថា ជីវិតយើងជាគ្រីស្តបរិស័ទរួចផុតពីទុក្ខលំបាក និងទុក្ខវេទនានោះទេ។ ជីវិតរបស់គ្រីស្តបរិស័ទត្រូវយកគំរូតាមព្រះយេស៊ូដោយព្រមទទួលការឈឺចាប់ ការលំបាក ទុក្ខវេនា ទោះបីជាត្រូវបូជាជីវិតក៏ដោយត្រូវហ៊ានធ្វើ ដើម្បីផ្តល់សក្ខីភាពអំពីព្រះអង្គនៅក្នុងលោកយើងនេះ។

*"យើងខ្ញុំ គ្រាន់តែជាអ្នកបំរើធម្មតាប៉ុណ្ណោះ"*។ ទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់មិនមែនជារបៀបទិញបាន និងលក់បាន មិនមែនជារបៀបផ្តល់ឲ្យ ហើយទទួលមកវិញនោះដែរ។ វាមិនមែនជាអ្វីដែលយើងឲ្យទៅព្រះជាម្ចាស់ច្រើនយ៉ាងណាហើយសង្ឃឹមថានឹងទទួលពីព្រះអង្គវិញច្រើនយ៉ាងនោះទេ។ តែទំនាក់ទំនងរបស់យើងជាមួយព្រះអង្គគឺត្រូវផ្តល់សេចក្តីស្រលាញ់ និងការបម្រើទាំងស្រុង និងគ្មានលក្ខខណ្ឌថ្វាយព្រះអង្គវិញ។ មូលហេតុពិតប្រាកដដែលយើងមិនអាចទាមទារពីព្រះអង្គ គឺយើងម្នាក់ៗជាអ្នកជំពាក់បំណុលព្រះអង្គ ព្រោះព្រះអង្គបានប្រទានអ្វីៗទាំងអស់ដល់យើងរួមមាន កម្លាំង ទ្រព្យសម្បត្តិ ជាពិសេសជីវិតយើងគឺជាអំណោយពីព្រះអង្គ។ ហេតុនេះពេលបំពេញកិច្ចការរួច យើងត្រូវអរព្រះគុណព្រះជាម្ចាស់ និងពោលតាមព្រះបន្ទូលរបស់ព្រះយេស៊ូថា យើងខ្ញុំគ្រាន់តែជាអ្នកបំរើធម្មតាប៉ុណ្ណោះ គឺយើងខ្ញុំគ្រាន់តែបានបំពេញកិច្ចការដែលយើងខ្ញុំត្រូវធ្វើប៉ុណ្ណោះ។

### ថ្ងៃអាទិត្យ ទី២៨ នៃរដូវធម្មតា ឆ្នាំ គ (លក ១៧,១១-១៩)

ពេលព្រះយេស៊ូចូលទៅក្នុងភូមិមនុស្សឃ្លង់១០នាក់ ចេញមកទទួលស្វាគមន៍ព្រះអង្គ។ *"លោកគ្រូយេស៊ូអើយ! សូមអាណិតអាសូរយើងខ្ញុំផង"*។ សេចក្តីសង្ឃឹមតែមួយគត់របស់ពួកគេ គឺព្រះហឫទ័យអាណិតអាសូររបស់ព្រះយេស៊ូ ដែលជាព្រះគ្រូ និងព្រះអម្ចាស់របស់ពួកគេ ដែលពោរពេញដោយព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។

ព្រះយេស៊ូឆ្លើយតបទៅពួកគេដោយគ្មានស្ទាក់ស្ទើរ *"ចូរអ្នករាល់គ្នាទៅបង្ហាញខ្លួនឲ្យពួកបូជាចារ្យឃើញចុះ"*។ ស្តាប់តាមព្រះបញ្ជារបស់ព្រះយេស៊ូ នេះជារង្វាន់នៃជំនឿរបស់ពួកគេលើព្រះយេស៊ូ។ នៅសម័យនោះ លោកបូជាចារ្យមានអំណាចប្រកាសជាសាធារណៈថា ពួកគេបានជាស្អាតបរិសុទ្ធអាចចូលទៅក្នុងសង្គមបាន។

នៅក្នុងពិភពលោកមានកន្លែងមួយចំនួននៅតែមានការរើសអើងគ្នា ស្អប់គ្នា កេងប្រវ័ញ្ចផលប្រយោជន៍ និងបោះបង់គ្នាចោល។ មានមនុស្សរស់នៅតំបន់ដាច់ប្រយាលដោយការស្អប់ខ្ពើម មានការជិះជាន់កៀបសង្កត់ទទួលការឈឺចាប់បំផុត ។ល។ ទាំងនេះជាជំងឺឃ្លង់តាមរបៀបថ្មី។

ដូច្នេះហើយយើងដែលជាគ្រីស្តបរិស័ទត្រូវចេះសម្លឹងមើលសង្គម ដោយចិត្តមេត្តាករុណា និងអាណិតអាសូរដូចព្រះបិតាមានចំពោះយើង។ យើងត្រូវដឹងថា ចំពោះព្រះជាម្ចាស់ គ្មានមនុស្សកើតឃ្លង់ ឬសាសន៍ដទៃ ឬការរើសអើងអ្វីទេ តែទាំងអស់គ្នាជាគ្រួសារតែមួយ ពីព្រោះទាំងអស់គ្នាមានព្រះបិតាតែមួយ។ ហេតុនេះទាំងអស់គ្នាជាបងប្អូនដែលត្រូវស្រលាញ់ និងបំរើគ្នាទៅវិញទៅមក។

### ថ្ងៃអាទិត្យ ទី២៩ នៃរដូវធម្មតា ឆ្នាំ គ (លក ១៨,១-៨)

ស្នូលសំខាន់នៃព្រះបន្ទូលថ្ងៃនេះគឺការអធិដ្ឋាន។ ពេលអធិដ្ឋាន យើងនិយាយទៅព្រះជាម្ចាស់ដោយពាក្យ ៖ កោតសរសើរលើកតម្កើង អរព្រះគុណ អង្វរសកល និងទូលអង្វរ។

ព្រះយេស៊ូសុំឲ្យយើងអធិដ្ឋាន ដោយទូលសុំព្រះជាម្ចាស់តាមសេចក្តីត្រូវការរបស់យើងម្នាក់ៗ ដូចស្ត្រីមេម៉ាយក្រីក្រដែលស្វែងរកយុត្តិធម៌ពីចៅក្រមក្នុងពាក្យប្រស្នា។ ព្រះយេស៊ូធ្លាប់ប្រៀបធៀបព្រះជាម្ចាស់ជាមួយនឹងឪពុកម្តាយនៅក្នុងលោកិយនេះ ដែលតែងតែផ្តល់ របស់ល្អទៅកូន។ យើងមិនឲ្យដុំថ្មទៅកូនទេ នៅពេលគាត់សុំនំប៉័ង ហើយក៏មិនឲ្យសត្វពស់អាសិរពិសទៅកូនដែរ នៅពេលកូនសុំពងមាន់នោះ។ ហេតុនេះហើយ ឲ្យយើងជឿជាក់លើពាក្យទូលអង្វររបស់យើងទៅព្រះបិតាតាមសេចក្តីត្រូវការ ដោយយកព្រះបន្ទូលរបស់ព្រះយេស៊ូមកទុកក្នុងចិត្តគឺ *"...ចំណង់បើព្រះជាម្ចាស់វិញ ព្រះអង្គរឹតតែរកយុត្តិធម៌ឲ្យអស់អ្នកដែលព្រះអង្គបានជ្រើសរើស ហើយដែលអង្វរព្រះអង្គទាំងយប់ទាំងថ្ងៃ ព្រះអង្គគ្រាន់តែបង្អង់ប៉ុណ្ណោះ។ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះអង្គនឹងរកយុត្តិធម៌ឲ្យគេក្នុងរយៈពេលដ៏ខ្លី"*។ ត្រូវតែអធិដ្ឋានជានិច្ច មិនត្រូវរសាយចិត្តឡើយ។

### ថ្ងៃអាទិត្យ ទី៣០ នៃរដូវធម្មតា ឆ្នាំ គ (លក ១៨,៩-១៤)

ក្នុងអត្ថបទសប្តាហ៍នេះ នៅក្នុងប្រស្នារបស់ព្រះយេស៊ូ មានម្នាក់ខាងគណៈផារីស៊ី និងម្នាក់ទៀតជាអ្នកទារពន្ធអធិដ្ឋាននៅក្នុងព្រះវិហារ។ អ្នកខាងគណៈផារីស៊ី កំពុងចាប់កំហុសអ្នកទារពន្ធនៅក្នុងពាក្យអធិដ្ឋានរបស់គាត់។

យើងអាចសួរសំណួរថា៖ តើហេតុដូចម្តេចបានព្រះជាម្ចាស់ស្រលាញ់អ្នកបាបទៅវិញ? វាជាការពិតណាស់ អ្នកបាបត្រូវការសេចក្តីស្រលាញ់ពីព្រះជាម្ចាស់ និងត្រូវការជំនួយពីព្រះជាម្ចាស់។ ព្រះជាម្ចាស់មិនទតមើលអ្នកបាប ថាជាអ្នកទោសប្រឆាំងនឹងព្រះអង្គទេ។ តែផ្ទុយទៅវិញ ព្រះអង្គទតមើលអ្នកបាបជាមនុស្សដែលបានប្រព្រឹត្តកំហុស ត្រូវការព្យាបាល និងធ្វើឲ្យស្អាតបរិសុទ្ធឡើងវិញ។

*"ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់ប្រោសអ្នកទារពន្ធនេះឲ្យបានសុចរិត ហើយគាត់ត្រឡប់ទៅផ្ទះវិញ រីឯបុរសខាងគណៈផារីស៊ីមិនបានសុចរិតទេ"*។ ហេតុអ្វីអ្នកធ្វើតាមវិន័យមិនបានសុចរិត តែអ្នកបាបមិនគោរពវិន័យបានសុចរិតទៅវិញ?

អ្នកទារពន្ធបានសុំជំនួយពីព្រះជាម្ចាស់សម្រាប់ការសង្គ្រោះរបស់គាត់។ គាត់បន្ទាបខ្លួន ដោយទទួលសារភាពបាបថា គាត់ជាអ្នកបាប។ គាត់មិនអាចសង្គ្រោះខ្លួនឯងដោយកំលាំងរបស់គាត់ផ្ទាល់ទេ។ ចំពោះគាត់ មានតែព្រះជាម្ចាស់មួយព្រះអង្គគត់អាចសង្គ្រោះគាត់បាន។ នេះជាមូលហេតុគាត់ទូលអង្វរព្រះជាម្ចាស់ "ឱព្រះជាម្ចាស់អើយ! សូមអាណិតមេត្តាទូលបង្គំជាមនុស្សបាបផង"។ ផ្ទុយពីអ្នកទារពន្ធ អ្នកខាងគណៈផារីស៊ីជាមនុស្សល្អ គោរពវិន័យ តមអាហារ ថ្វាយតង្វាយ១ភាគ១០ដល់ព្រះជាម្ចាស់។ គាត់មិនបានសុំការសង្គ្រោះពីព្រះជាម្ចាស់ទេ។ គាត់គិតថា ទង្វើរបស់គាត់អាចសង្គ្រោះខ្លួនឯងបានហើយ។ គាត់ធ្លាក់ទៅក្នុងអំពើបាបអួតខ្លួនដោយមិនដឹងខ្លួន។ ការអួតខ្លួន លើកតម្កើងខ្លួនដោយខ្លួនឯងជាបាបធ្ងន់របស់គាត់។ យើងត្រូវចងចាំព្រះបន្ទូលរបស់ព្រះអម្ចាស់ថា៖ អ្នកណាលើកតម្កើងខ្លួន អ្នកនោះនឹងត្រូវគេបន្ទាបចុះ រីឯអ្នកដែលបន្ទាបខ្លួននឹងត្រូវគេលើកតម្កើងវិញ។

### ថ្ងៃអាទិត្យ ទី៣១ នៃរដូវធម្មតា ឆ្នាំ គ (លក ១៩,១-១០)

នៅក្នុងអត្ថបទនេះ លោកសាខេចង់ឃើញព្រះយេស៊ូមានភិនភាគយ៉ាងណា។ តែគាត់មានមាឌតូច ហើយមនុស្សចោមរោមជុំវិញព្រះយេស៊ូ ជាហេតុដែលគាត់មិនអាចមើលព្រះយេស៊ូឃើញទេ។ យើងក៏ដូចលោកសាខេដែរ ជាញឹកញាប់ យើងចង់ឃើញព្រះយេស៊ូនៅក្នុងចំណោមមនុស្សច្រើនយ៉ាងនេះ តែយើងមិនអាចមើលឃើញព្រះយេស៊ូនៅក្នុងជីវិតរបស់យើង ពីព្រោះមានមនុស្សជាច្រើនជាឧបសគ្គ និងរបៀបគិតរបស់ពួកគេជះឥទ្ធិពលលើជីវិតរបស់យើងដែរ។ ដើម្បីមើលឃើញព្រះយេស៊ូច្បាស់ ពេលខ្លះយើងត្រូវចេញឆ្ងាយពីហ្វូងមនុស្ស និងភាពគ្រោះថ្នាក់ដល់តម្លៃជីវិតយើង។

ព្រះយេស៊ូមិនប្រកាន់អ្នកបាបទេ។ *"...លោកសាខេអើយ! សូមអញ្ជើញចុះមកជាប្រញាប់ ដ្បិតថ្ងៃនេះ ខ្ញុំត្រូវស្នាក់នៅផ្ទះលោក"*។ មនុស្សម្នាចាប់ផ្តើមរិះគន់ព្រះយេស៊ូ៖ មើល៍! លោកនេះទៅស្នាក់នៅផ្ទះមនុស្សបាប!។ ក្នុងជីវិតរស់នៅរបស់យើង មិនខុសគ្នាពីអស់អ្នកដែលរិះគន់ព្រះយេស៊ូនោះទេ គឺយើងវិនិច្ឆ័យមនុស្សតែសម្បកក្រៅដែរ។ សូមឲ្យយើងចេះមើលអ្នកដទៃដូចរបៀបព្រះអង្គសំឡឹងមើលយើងដែរ។ ភាពដ៏វិសុទ្ធរបស់យើងម្នាក់ៗគឺនៅពេលយើងធ្លាក់ខ្លួនប្រព្រឹត្តអំពើបាបហើយ តែភ្ញាក់ខ្លួនកែប្រែចិត្តគំនិតហើយត្រឡប់មករកព្រះជាម្ចាស់វិញ។ ដូចលោកសាខេបានធ្វើ គឺភាពល្អលេចចេញពីជីវិតរបស់លោកដែលជាអ្នកបាប ៖ *បពិត្រព្រះអម្ចាស់! ទូលបង្គំនឹងចែកទ្រព្យសម្បត្តិរបស់ទូលបង្គំចំនួនពាក់កណ្តាលដល់មនុស្សក្រីក្រ។ ប្រសិនបើទូលបង្គំទារពន្ធពីអ្នកណាហួសកម្រិត ទូលបង្គំនឹងសងអ្នកនោះវិញមួយជាបួន*។

ព្រះយេស៊ូមកស្វែងរកអស់អ្នកដែលវង្វេង ព្រះអង្គមិនបានមកដើម្បីស្វែងរកអ្នកល្អទេ គឺមករកអស់អ្នកដែលដាច់ទំនាក់ទំនងឆ្ងាយពីព្រះជាម្ចាស់ ដើម្បីគេវិលមករកព្រះអង្គវិញ។ ហេតុនេះហើយ យើងដែលជាអ្នកបាបគ្រប់គ្នាសូមកុំអស់សង្ឃឹម ដោយដឹងថាព្រះអង្គនៅតែតាមស្វែងរកយើងជានិច្ច។



# វិទ្យាស្ថានសន្តប៉ូល


អាសយដ្ឋាន៖ ភូមិអង្គគគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ

Tel: 032 639 0002/ 032 639 0003 | E: spi.takeo@gmail.com | W : www.spi.edu.kh


## ថ្នាក់បរិញ្ញាបត្រ

### មហាវិទ្យាល័យព័ត៌មានវិទ្យា
### Faculty of Information Technology

- វិស្វកម្មកម្មវិធី Software Engineering
- ទូរគមនាគមន៍ និងបណ្ដាញ Telecommunication and Network

### ដេប៉ាតឺម៉ង់អក្សរសាស្ត្រអង់គ្លេស
### Department of English Literature

- អប់រំភាសាអង់គ្លេស Teaching English as Foreign Language
- ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង English for Communication

### ដេប៉ាតឺម៉ង់គ្រប់គ្រងទេសចរណ៍
### Department of Tourism Management

- គ្រប់គ្រងទេសចរណ៍ Tourism Management

### ដេប៉ាតឺម៉ង់ក្សេត្រសាស្ត្រ
### Department of Agronomy

- ក្សេត្រសាស្ត្រ Agronomy

### ដេប៉ាតឺម៉ង់សង្គមកិច្ច
### Department of Social Work

- សង្គមកិច្ច Social Work

## ថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស

- អភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ Software Development
- គ្រប់គ្រងប្រព័ន្ធ និងបណ្ដាញកុំព្យូទ័រ System and Network Administration
- បង្រៀនភាសាអង់គ្លេស English Language
- សណ្ឋាគារ និងបដិសណ្ឋារកិច្ច Hotel and Hospitality
- ផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែ Fruit and Vegetable Crop Production
- ជំនាញកែច្នៃអាហារ Food Processing
- ប្រព័ន្ធកសិកម្មចម្រុះ Integrated Farming System

## លក្ខខណ្ឌចូលរៀន

១. បេក្ខជនត្រូវមានសញ្ញាបត្រទុតិយភូមិ (ជាប់ថ្នាក់ទី១២) ឬសញ្ញាបត្រដែលមានតម្លៃស្មើ សម្រាប់ចូលរៀនថ្នាក់បរិញ្ញាបត្រ

២ បេក្ខជនធ្លាក់ថ្នាក់ទី១២អាចចូលរៀន ថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស




**ចាប់ផ្ដើមលក់ពាក្យ និងទទួលពាក្យ**
**ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ**

- ចូលរៀនវគ្គបំប៉ន ខែកញ្ញា ឆ្នាំ២០១៦
- ចូលរៀនឆមាសទី១ ខែវិច្ឆិកា ឆ្នាំ២០១៦